# ព្រំដែននៃកម្មវិធីសហគមន៍ដឹកនាំអនាម័យទាំងស្រុង (SLH)៖ នវានុវត្តន៍ និងចំណេះដឹង



## ការដោះស្រាយការធ្លាំងធ្លាត់

Sophie Hickling, ទីប្រឹក្សា MG អាហ្វ្រិក

ខែ កញ្ញា ឆ្នាំ ២០២០

The Sanitation Learning Hub at institute of development studies
https: //sanitationlearninghub.org

# អំពី The Sanitation Learning Hub

IDS បាន និងកំពុងគាំទ្រដល់កម្មវិធីសហគមន៍ដឹកនាំអនាម័យទាំងស្រុង (SLH) តាំងពីពេលចាប់ផ្ដើមដំបូង។ SLH បានក្លាយជាចលនាអន្តរជាតិដែលធ្វើឱ្យមានការទទួលស្គាល់ IDS ជា The Sanitation Learning Hub។

The Sanitation Learning Hub មានគោលបំណងស្វែងយល់ពីតថភាពតាមមូលដ្ឋានស្ដីពីការអនុវត្ត SLH ក៏ដូចជារៀនសូត្រចែករំលែក និងលើកកម្ពស់ការអនុវត្តល្អ គំនិតនិងនវានុវត្តន៍ដែលជំរុញឱ្យមាននិរន្តរភាពនិងវិសាលភាព។ យើងខិតខំធ្វើយ៉ាងណារក្សាទំនាក់ទំនងជាមួយសហគមន៍ SLH និងផ្ដល់ព័ត៌មានត្រឹមត្រូវដល់សហគមន៍ទាំងនោះព្រមឱកាសសម្រាប់ការឆ្លុះបញ្ចាំង រៀនសូត្រនិងផ្លាស់ប្ដូរចំណេះដឹងជាប់ជាប្រចាំ។ យើងបានសហការជាមួយអ្នកអនុវត្តអ្នកតាក់តែងគោលនយោបាយ អ្នកស្រាវជ្រាវ និងអ្នកពាក់ព័ន្ធផ្សេងទៀតដែលធ្វើការក្នុងផ្នែកអភិវឌ្ឍន៍អនាម័យនិងសហគមន៍ពាក់ព័ន្ធ។

គោលដៅរួមនៃ The Sanitation Learning Hub គឺដើម្បីរួមចំណែកពង្រឹងសេចក្ដីថ្លៃថ្នូរ សុខភាពនិងសុខុមាលភាពរបស់កុមារស្រ្តី និងបុរសក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ព្រោះពួកគេកំពុងប្រឈមនឹងផលវិបាកនៃការគ្មាន ឬកង្វះអនាម័យ។

គម្របមុខ ៖

ការប្រើប្រាស់ឥដ្ឋរាងចតុកោណព្នាយ ដើម្បីសង់រណ្ដៅរាងរង្វង់លើដីល្បាយខ្សាច់ក្នុងប្រទេសម៉ាឡាវី ក្នុងអំឡុងដំណើរការរចនាបង្គន់បែបចូលរួម។ សូមមើលឯកសារទី ១ នៃកម្រងឯកសារ "ព្រំដែននៃកម្មវិធីសហគមន៍ដឹកនាំអនាម័យទាំងស្រុង"។

ក្រេឌីត ៖ UNICEF/BEN COLE

# ការដោះស្រាយការផ្លាំងផ្លាត់

Sophie Hickling, ទីប្រឹក្សា MG អាហ្វ្រិក

*គ្មានការចម្លងតាម៖* អ្នកប្រហែលជាមិនអាចកែប្រែ ផ្ទេរ ឬផ្អែកលើវណ្ណកម្មនេះបានទេ។

អ្នកប្រើប្រាស់អាចថតចម្លង ចែកចាយ ដាក់បង្ហាញ បកប្រែ ឬយកវណ្ណកម្មនេះទៅប្រើប្រាស់ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរ។ សម្រាប់ការប្រើប្រាស់ឡើងវិញ ឬការចែកចាយ អ្នកត្រូវបញ្ជាក់ឱ្យបានច្បាស់ពីលក្ខខណ្ឌការដកស្រង់ត្រឹមត្រូវ៖ ហ៊ិកគ្លីង, ស. (២០១៩) 'ការដោះស្រាយការភ្លាំងភ្លាត់', ព្រំដែននៃកម្មវិធីសហគមន៍ដឹកនាំអនាម័យទាំងស្រុង៖ នវានុវត្តន៍ និងចំណេះដឹង ១៥, ប្រាយតុន៖ IDS, DOI: 10.19088/SLH.2020.004

បោះពុម្ពលើកទី ១ នៅឆ្នាំ ២០១៩
រក្សាសិទ្ធិថតចម្លង©វិទ្យាស្ថានសិក្សាអភិវឌ្ឍន៍ ឆ្នាំ ២០១៩
រក្សាសិទ្ធិមួយចំនួន ៖ សម្រាប់ព័ត៌មានលម្អិត សូមមើលអាជ្ញាប័ណ្ណសិទ្ធិថតចម្លង។

ISBN 978-1-78118-706-7
DOI: 10.19088/SLH.2020.004 (https://doi.org/10.19088/SLH.2020.004)

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង ៖
The Sanitation Learning Hub, Institute of Development Studies, University of Sussex, Brighton, BN1 9RE
Tel: +44 (0)1273 606261
Email: SLH@ids.ac.uk
Web: https://sanitationlearninghub.org

កម្រងឯកសារនេះត្រូវបានផ្តល់អាជ្ញាប័ណ្ណក្រោមអាជ្ញាប័ណ្ណ the Creative Commons Attribution-Non-Commercial-NoDerivs 3.0 Unported License (http://creativecommons.org/licenses/by-nc-nd/3.0/)។

*ការសំអាង៖* អ្នកត្រូវសំអាងវណ្ណកម្មនេះតាមរបៀបដែលកំណត់ដោយអ្នកនិពន្ធ ឬអ្នកផ្តល់អាជ្ញាប័ណ្ណ។
*មិនមែនសម្រាប់គោលបំណងពាណិជ្ជកម្ម៖* អ្នកប្រហែលជាមិនអាចប្រើប្រាស់វណ្ណកម្មនេះសម្រាប់គោលបំណងពាណិជ្ជកម្មបានទេ។
អាជ្ញាប័ណ្ណនៃវណ្ណកម្មនេះ។ ប្រសិនបើអ្នកប្រើប្រាស់វណ្ណកម្មនេះ យើងស្នើឱ្យអ្នកយោងតាមគេហទំព័រ SLH (https://sanitationlearninghub.org) រួចបញ្ជូនសំណៅចម្លងវណ្ណកម្មនេះ ឬតំណភ្ជាប់សម្រាប់ការប្រើប្រាស់តាមអនឡាញ តាមអាសយដ្ឋាន៖ The Sanitation Learning Hub, Institute of Development Studies, University of Sussex, Brighton, BN1 9RE, UK (SLH@ids.ac.uk)។

ឯកសារនេះ ត្រូវបានផ្តល់ហិរញ្ញប្បទាន ដោយទីភ្នាក់ងារកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត Sida។ ទស្សនៈដែលបានលើកឡើងក្នុងក្នុងឯកសារនេះមិនសុទ្ធតែឆ្លុះបញ្ចាំងពីទស្សនៈរបស់ Sidaឡើយ។ ការទទួលខុសត្រូវលើខ្លឹមសារឯកសារនេះជាបន្ទុកទាំងស្រុងរបស់អ្នកនិពន្ធ។

Sida

## សេចក្តីថ្លែងអំណរគុណ

អ្នកនិពន្ធសូមអរគុណដោយស្មោះចំពោះអ្នកផ្តល់ព័ត៌មានសំខាន់ទាំងអស់នៅថ្នាក់ជាតិ តំបន់ និងសកលដែលបានចែករំលែកចំណេះដឹងដ៏មានតម្លៃ និងបទពិសោធន៍តាមមូលដ្ឋានរបស់ខ្លួនស្តីពីការភ្លាំងភ្លាត់។

សូមអរគុណ Matt Bond, Sue Cavill, Jamie Myers, Andrew Robinson, Paul Tyndale-Biscoe, និង Naomi Vernon ដែលបានពិនិត្យឡើងវិញលើពង្រាងឯកសារនេះ និងផ្តល់មតិយោបល់ និងគំនិតល្អៗ។

creative commons

# ការដោះស្រាយការតាំងតប្បាត់

## សេចក្តីផ្តើម

ឯកសារទី ១៤ នៃកម្រងឯកសារ "ព្រំដែននៃកម្មវិធីសហគមន៍ដឹកនាំអនាម័យទាំងស្រុង" ផ្តោតសំខាន់លើការយល់ឃើញ និងការអនុវត្តបច្ចុប្បន្នពាក់ព័ន្ធនឹងការដោះស្រាយការភ្លាំងភ្លាត់នៃការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុង។ ឯកសារនេះពិនិត្យមើលរបៀបកំណត់ និងកត់សម្គាល់ការភ្លាំងភ្លាត់ និងគំរូផ្សេងៗនៃការភ្លាំងភ្លាត់ដែលរកឃើញក្រោយការប្រកាស ការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាល ទាំងស្រុង។ មានឯកសារជាច្រើនលើកឡើងពីរបៀបបង្កើតកម្មវិធីសហគមន៍ដឹកនាំអនាម័យទាំងស្រុងដែលអាចទប់ស្កាត់ មិនឱ្យមានការភ្លាំងភ្លាត់ប៉ុន្តែឯកសារនេះផ្តោតសំខាន់លើរបៀបស្តារការភ្លាំងភ្លាត់ ដែលបានកើតឡើង។ គួរកត់សម្គាល់ថា យុទ្ធសាស្ត្រដែលបានប្រើប្រាស់សម្រាប់ការស្តារការភ្លាំងភ្លាត់ និងយុទ្ធសាស្ត្រដែលបានប្រើប្រាស់ជាមុនដើម្បីបង្កើតកម្មវិធីដែលអាចទប់ស្កាត់ការភ្លាំងភ្លាត់មានភាពច្រំដែលនៅកម្រិតណាមួយ។

ការពិនិត្យឡើងវិញលើឯកសារមានស្រាប់បង្ហាញថា មានភស្តុតាងតិចតួចស្តីពីរបៀបស្តារការភ្លាំងភ្លាត់ ហើយភស្តុតាងដែលមាន និងការណែនាំនានា ហាក់ផ្តោតលើការទប់ស្កាត់។ ការពិនិត្យឡើងវិញនេះចាប់ផ្តើមលើកឡើងពីចំណុចខ្វះខាតនេះ។ អ្នកអនុវត្តន៍គួរប្រើប្រាស់ក្របខណ្ឌស្តីពីគំរូនៃការភ្លាំងភ្លាត់ដែលបានលើកឡើង និងផ្នែកស្តីពី*កត្តាបង្កការភ្លាំងភ្លាត់* ដើម្បីស្វែងយល់ពីប្រភេទ និងកម្រិតនៃការភ្លាំងភ្លាត់កន្លងមក រួចប្រើប្រាស់ឧទាហរណ៍ក្នុងផ្នែកស្តីពីការដោះស្រាយការភ្លាំងភ្លាត់ដើម្បីកំណត់រកការឆ្លើយតបចំពោះការភ្លាំងភ្លាត់ដែលអាចកើតឡើង។

មាន "អត្រាភ្លាំងភ្លាត់នៃការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាល ទាំងស្រុងប្រែប្រួលតាមប្រទេសនានា។ ការពិនិត្យតាមដានការភ្លាំងភ្លាត់ នៃការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុង មិនមានលក្ខណៈជាប្រព័ន្ធឡើយ ទោះបីជាមានការកត់សម្គាល់ជារួមពីបញ្ហានេះក្តី។ ចាំបាច់ត្រូវកំណត់រកការអនុវត្តថ្មីៗក្នុងការដោះស្រាយ ការភ្លាំងភ្លាត់ក្នុងតំបន់ឱ្យបានឆាប់រហ័ស និងចែករំលែកឱ្យបានទូលំទូលាយ"។

*សិក្ខាសាលាស្តីពីអនាម័យជនបទនៅតំបន់អាហ្វ្រិកខាងកើតនិងខាងត្បូង, IDS ២០១៨៖ https://www.communityledtotalsanitation.org/regional-africa-sharingand-learning-workshops-2018)*

ក្រៅពីការពិនិត្យឡើងវិញ លើឯកសារមានស្រាប់នេះ[1] យើងបានធ្វើបទសម្ភាសន៍ស៊ីជម្រៅជាមួយអ្នកផ្តល់ព័ត៌មានសំខាន់នៅកម្រិតសកល តំបន់ និងប្រទេស។ អ្នកផ្តល់ព័ត៌មានសំខាន់ត្រូវបានជ្រើសរើសដោយមានគោលបំណងច្បាស់លាស់ ដើម្បីកំណត់រកបទពិសោធន៍ និងនវានុវត្តន៍ក្នុងការដោះស្រាយការភ្លាំងភ្លាត់ក្នុងវិស័យនេះ។

[1] គួរកត់សម្គាល់ថា ការពិនិត្យឡើងវិញលើឯកសារមានស្រាប់មិនមានលក្ខណៈជាប្រព័ន្ធទេ ប៉ុន្តែផ្អែកលើការស្វែងរកឯកសារនានា (ការពិនិត្យឡើងវិញឱ្យគ្នាទៅវិញទៅមក ឯកសារដែលបានបោះពុម្ពផ្សាយ និងឯកសារមិនទាន់បានបោះពុម្ពផ្សាយ) ដែលលើកឡើងទាំងស្រុង ឬដោយផ្អែកពីការភ្លាំងភ្លាត់នៃការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុង។ ការសម្ភាស់អ្នកផ្តល់ព័ត៌មានសំខាន់ (KIIs) បានផ្តល់ប្រភពរបាយការណ៍ ករណីសិក្សា និងឯកសារព្រាងសម្រាប់ជាជំនួយដល់ការពិនិត្យឡើងវិនេះ។

# តើអ្វីជាការភ្លាំងភ្លាត់?



បង្គន់ដែលគេលែងប្រើ, Kilifi, ប្រទេសកេនយ៉ា ឆ្នាំ ២០១០។ *ក្រេឌីត៖ Ross Kidd*

ការភ្លាំងភ្លាត់សំដៅលើការវិលទៅរកឥរិយាបថគ្មានអនាម័យពីមុន ឬអសមត្ថភាពរបស់សមាជិកសហាគមន៍មួយចំនួន ឬទាំងអស់ ក្នុងការបន្តបំពេញលក្ខណៈវិនិច្ឆ័យទាំងអស់នៃការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុង (Jerneck et al. 2016)។

និយមន័យផ្សេងទៀត ផ្តោតលម្អិតលើការបន្ទោរបង់ពាសវាលពាសកាលផ្ទាល់ (ភាគរយគ្រួសារដែលគេរកឃើញថាបានវិលទៅអនុវត្តការបន្ទោរបង់ពាសវាលពាសកាលឡើងវិញ) ឬផ្តោតលើលទ្ធភាពទទួលបាន ហេដ្ឋារចនាសម្ព័ន្ធអនាម័យ (ភាគរយគ្រួសារដែលលែងប្រើប្រាស់បង្គន់គ្រួសារ។ និយមន័យនេះដែលងាយស្រួលវាស់វែង ប៉ុន្តែកាន់តែប្រាស់ចាកពីការលុបបំបាត់ ការបន្ទោរបង់ពាសវាលពាសកាល ដែលជាលទ្ធផលឥរិយាបថ ក្នុងកម្មវិធីសហគមន៍ដឹកនាំអនាម័យទាំងស្រុង (USAID 2018)។

> "ប្រទេសនានាមិនបានដាក់កម្រិតលើនិយមន័យនៃការភ្លាំងភ្លាត់ ឬភាពអវិជ្ជមានរបស់វាឡើយ។ ផ្ទុយទៅវិញ ប្រទេសទាំងនោះផ្តោតលើថាតើមានការយកចិត្តទុកដាក់លើការភ្លាំងភ្លាត់ ឬទេ និងរបៀបដោះស្រាយបញ្ហានេះ"។
>
> *ការសម្ភាសអ្នកផ្តល់ព័ត៌មាន សំខាន់នៅតំបន់អាស៊ី*

គេមិនអាចកំណត់លក្ខណៈវិនិច្ឆ័យនៃការភ្លាំងភ្លាត់តាមរបៀបរួមមួយ សម្រាប់ការប្រៀបធៀបអត្រានៃការភ្លាំងភ្លាត់តាមបណ្តាប្រទេសនានាបានឡើយ ហើយការធ្វើដូច្នេះក៏គ្មានប្រយោជន៍អ្វីដែរ ព្រោះការភ្លាំងភ្លាត់ ពាក់ព័ន្ធនឹងនិយមន័យនៃការបញ្ឈប់ការ

បន្ទោរបង់ពាសវាលពាសកាលទាំងស្រុង និងលក្ខណៈវិនិច្ឆ័យដែលបានប្រើប្រាស់ ក្នុងពិធីសារនៃការផ្ទៀងផ្ទាត់ថ្នាក់ជាតិ។ ប្រការសំខាន់គឺថាតើមានការកំណត់ តាមដាន និងលើកឡើងពីការភ្លាំងភ្លាត់នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឬទេ។

"ការភ្លាំងភ្លាត់មានវិសាលភាពធំទូលាយលើសពីវិធានការជាក់លាក់មួយ"។ *ការសម្ភាសអ្នកផ្តល់ព័ត៌មានសំខាន់នៅតំបន់អាហ្វ្រិកខាងលិច*

ការប្រៀបធៀបលក្ខណៈវិនិច្ឆ័យ សម្រាប់ការបញ្ជាក់ការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុង អាចរកបានក្នុងឯកសារផ្សេងទៀត (Bevan and Thomas 2013; Jerneck et al. 2016) ដូចការពិភាក្សាពីបញ្ហាប្រឈមក្នុងការកំណត់និយមន័យ និងការពិនិត្យតាមដាន ការភ្លាំងភ្លាត់នៃការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុងដែរ (Pasteur 2017; Cavill et al. 2015; USAID 2018)។ ជារួម៖

- ការភ្លាំងភ្លាត់ ត្រូវបានកំណត់ទៅតាមលក្ខណៈវិនិច្ឆ័យដែលបានប្រើប្រាស់សម្រាប់ការបញ្ជាក់ពីការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុង តាំងពីដើមទី។ តាមពិតទៅ គួរតែគ្មានលក្ខណៈវិនិច្ឆ័យនៃការភ្លាំងភ្លាត់ទេ។ អ្វីដែលចាំបាច់គឺត្រូវមានវិធីសាស្រ្តជាក់លាក់ក្នុងការញែកនិន្នាការអវិជ្ជមាន នៃការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុង ពីការភ្លាំងភ្លាត់បណ្តោះអាសន្ន ឬ "អាចទទួលយកបាន"។

- ប្រសិនបើ លក្ខណៈវិនិច្ឆ័យនៃការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុង មិនស៊ីគ្នាទេនោះ គេមិនអាចកំណត់និយមន័យនៃការភ្លាំងភ្លាត់ក្នុងបរិបទនានាបានទេ។ លក្ខណៈវិនិច្ឆ័យដែលបានជ្រើសរើស ធ្វើឱ្យមានភាពខុសគ្នាយ៉ាងខ្លាំងលើលទ្ធផលនៃការភ្លាំងភ្លាត់។ ឧ. ក្នុងការសិក្សាមួយការភ្លាំងភ្លាត់មានអត្រា ១៣% នៅពេលគេពិចារណាពីលទ្ធភាពទទួលបានអនាម័យ មានអត្រា ៦៣% នៅពេលគេពិចារណាពីកន្លែងលាងសម្អាតដៃ និងមានអត្រា ៩២% នៅពេលគេពិចារណាពីលក្ខណៈវិនិច្ឆ័យទាំងអស់នៃការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុង (Tyndale-Biscoe et al. 2013)។

- ស្ថានភាពដើមគ្រា សម្រាប់ការបញ្ជាក់ការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុង អាចប្រើប្រាស់ឧបករណ៍ និងក្រុមផ្សេងៗដើម្បីតាមដានការត្រួតពិនិត្យ។ **ក្នុងករណីដែលការបញ្ជាក់ការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុង មិនសូវមានគុណភាព ការពិនិត្យលម្អិតលើនិរន្តរភាពអាចកម្រិតឱ្យសហគមន៍សម្រេចបានស្តង់ដារមួយដែលមិនធ្លាប់មានតាំងពីដំបូង។ ក្រៅពីនេះ អាចមានការបន្ថែមលក្ខណៈវិនិច្ឆ័យ ជាចំណុចដែលមិនត្រូវបានពិចារណានៅពេលសហគមន៍បានប្រកាសដំបូងពីការបញ្ឈប់ ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុង (ឧ. ការបោះចោលលាមកកុមារដោយសុវត្ថិភាព)។ ការភ្លាំងភ្លាត់ក្នុងឧទាហរណ៍នេះ សំដៅលើការមិនបំពេញចំណុចដៅថ្មីមួយ។**

- គេអាចបំពេញលក្ខណៈវិនិច្ឆ័យជាក់លាក់ នៃការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុងបានក្នុងរយៈពេលខ្លី ឬ "សម្រាប់ជាការបង្ហាញ" ក្នុងអំឡុងពេលផ្ទៀងផ្ទាត់។ ប៉ុន្តែនៅពេលគ្មានការពិនិត្យតាមដានយូរអង្វែងលើលក្ខណៈវិនិច្ឆ័យទាំងអស់ ការភ្លាំងភ្លាត់នឹងកើតឡើងដោយគ្មានអ្នកដឹង។ ចំណុចនេះពាក់ព័ន្ធនឹងលក្ខណៈវិនិច្ឆ័យនៃការបោះចោលលាមកកុមារ និងការលាងសម្អាតដៃដែលហាក់ភ្លាំងភ្លាត់ លឿនជាងលក្ខណៈវិនិច្ឆ័យផ្សេងទៀត។

ក្នុងករណីដែលរកឃើញការភ្លាំងភ្លាត់ ច្រើនតែគ្មានវិធានការផ្លូវការដើម្បីដកហូតស្ថានភាពបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុង[2] លើកលែងតែប្រទេសអូត្យពីរដែលប្រព័ន្ធដោតទង់ជាតិ បង្ហាញពីស្ថានភាពបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុងរបស់ភូមិមួយ និងអាចទម្លាក់កម្រិត ប្រសិនបើមានការភ្លាំងភ្លាត់កើតឡើង។

## ការពិនិត្យតាមដានការភ្លាំងភ្លាត់

ប្រទេសភាគច្រើនបានបង្កើតនីតិវិធីសម្រាប់ការផ្ទៀងផ្ទាត់ និងបញ្ជាក់ស្ថានភាពបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុង ដែលរួមមានការវាស់វែងឥរិយាបថ និងហេដ្ឋារចនាសម្ព័ន្ធ។ ភាគច្រើន ការពិនិត្យតាមដានសូចនាករនៃការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុងក្នុងសហគមន៍មួយ នឹងត្រូវបញ្ចប់នៅពេលមានការប្រកាសពីការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុង។

ការអង្កេតនិរន្តរភាពផ្អែកតាមកម្មវិធី ដូចជា ការអង្កេតដែលធ្វើឡើងដោយ UNICEF, SNV និងអ្នកពាក់ព័ន្ធផ្សេងទៀត បានផ្តល់ទិន្នន័យបន្ទាប់បន្សំក្រោយចន្លោះពេលមួយ ជាទិន្នន័យដែលគេអាចប្រើប្រាស់សម្រាប់វាស់វែងកម្រិតនៃការភ្លាំងភ្លាត់ ដែលបានកើតឡើង។ ការអង្កេតទ្រង់ទ្រាយធំ និងស្មុគស្មាញទាំងនេះជួយពង្រឹងការយល់ដឹងពីបញ្ហាយូរអង្វែងកម្មវិធី និងជាការត្រួតពិនិត្យពីខាងក្រៅលើប្រភពទិន្នន័យទូទៅ។

ទោះជាយ៉ាងណា ការមានប្រភពទិន្នន័យពីរ (ទិន្នន័យពីការប្រកាសការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុង និងទិន្នន័យពីការអង្កេតនិរន្តរភាពនៅអំឡុងពេលណាមួយ) នឹងផ្តល់ការយល់ដឹងតិចតួចពីវិធានការដែលបានធ្វើឡើង មិនថាការភ្លាំងភ្លាត់ដែលបានកត់សម្គាល់ នៅអំឡុងពេលណាមួយមានលក្ខណៈបណ្តោះអាសន្ន ឬអចិន្ត្រៃយ៍ ឬក៏និន្នាការជារួមកំពុងឆ្ពោះទៅរកនិរន្តរភាពកាន់តែប្រសើរនោះទេ។

ចាំបាច់ត្រូវមានការប្រមូលទិន្នន័យបន្តទៀត ក្រោយការប្រកាសពីការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុង ដើម្បីចាប់យកការភ្លាំងភ្លាត់នៃការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុង ហើយកម្មវិធីមួយចំនួនកំពុងឈានទៅរកការអង្កេតលម្អិតប្រចាំឆ្នាំ។ ទោះជាយ៉ាងណា មិនច្បាស់ថាតើប្រព័ន្ធព័ត៌មានពិនិត្យតាមដានសុខភាពជាប្រចាំអាចចាប់យកសូចនាករចម្រុះនៃការបញ្ឈប់ ការបន្ទោរបង់

---

[2]ការសម្ភាសអ្នកផ្តល់ព័ត៌មានសំខាន់៖ ប្រទេសឥណ្ឌា កេនយ៉ា ម៉ាលី នីហ្សេរីយ៉ា តង់ហ្សានី និងហ្សាំប៊ី

ពាសវាលពាសកាលទាំងស្រុងដែលពាក់ព័ន្ធនឹងឥរិយាបថជារួម ឬភាពខុសគ្នាក្នុងគ្រួសារ ឬយ៉ាងណានោះទេ។ ចំណុចចាំបាច់គឺត្រូវរក្សាតុល្យភាពដើម្បីអាចផ្ដល់ទិន្នន័យថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិសម្រាប់ការពិនិត្យតាមដានវឌ្ឍនភាព ឆ្ពោះទៅសម្រេចបានចំណុចដៅនៃលទ្ធភាពទទួលបានជាសកល ខណៈដែលរចនាសម្ព័ន្ធសហគមន៍ និងរដ្ឋាភិបាលមូលដ្ឋានដែលគាំទ្ររចនាសម្ព័ន្ធទាំងនោះ មានទិន្នន័យចម្រុះចាំបាច់សម្រាប់ការដោះស្រាយបញ្ហាភ្លាំងភ្លាត់ដោយផ្ទាល់។ គេអាចធ្វើការអង្កេតលម្អិតតាមដំណាក់កាលដើម្បីពិនិត្យផ្ទៀបនឹងទិន្នន័យធម្មតា និងពន្យល់ពីនិន្នាការនៃការភ្លាំងភ្លាត់កន្លងមក។

មានឧទាហរណ៍ជាច្រើន នៃប្រព័ន្ធត្រួតពិនិត្យការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុងដែលអាចពិនិត្យការប្រកាសក្រោយការភ្លាំងភ្លាត់ និងវឌ្ឍនភាពឆ្ពោះទៅរកការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុង (ឧ. ការត្រួតពិនិត្យតាមទូរស័ព្ទ-គេហទំព័រក្នុងប្រទេសហ្សាំប៊ី សៀវភៅគោលបញ្ជីសហគមន៍ក្នុងប្រទេសតង់ហ្សានីការដាក់ស្លាកភូមិសាស្ត្រក្នុងប្រទេសឥណ្ឌា និងការពិនិត្យក្រោយការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុងក្នុងប្រទេសម៉ាលី)។ គួរសិក្សាបន្ថែមទៀតពីឧទាហរណ៍ទាំងនេះ ដើម្បីពង្រីកការយល់ដឹងពីចំណុចដែលមានប្រសិទ្ធភាព និងបញ្ហាប្រឈម ក្នុងការជះឥទ្ធិពលលើការបន្តត្រួតពិនិត្យការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុង។

## គំរូនៃការភ្លាំងភ្លាត់

ការភ្លាំងភ្លាត់ហាក់កើតឡើងនៅគ្រប់កម្មវិធីសហគមន៍ដឹកនាំអនាម័យទាំងស្រុង ទាំងអស់ ប៉ុន្តែវាមិនសុទ្ធតែប៉ះពាល់ខ្លាំងដល់ការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុងនោះទេ។ គំរូផ្សេងៗនៃការភ្លាំងភ្លាត់លេចឡើងក្នុងសង្ខាក់មួយ(សូមមើលរូប ១)។ គួរកត់សម្គាល់ថា គំរូនៃការភ្លាំងភ្លាត់ ត្រូវបានកំណត់និយមន័យខុសៗគ្នាក្នុងឯកសារផ្សេងទៀត (ឧ. Jerneck et al. 2016)។ សម្រាប់ឯកសារនេះ ការប្រើប្រាស់ដ្យាក្រាមទំនាក់ទំនងបង្ហាញពីលក្ខណៈនៃការភ្លាំងភ្លាត់បណ្ដោះអាសន្ន និងផ្អែកតាមបរិបទ។

ការយល់ពីគំរូនៃការភ្លាំងភ្លាត់ និងកត្តារួមចំណែកបង្កការភ្លាំងភ្លាត់ គឺជាចំណុចចាប់ផ្ដើមសម្រាប់ការដោះស្រាយបញ្ហានេះ។ ឧ. ការឆ្លើយតបចំពោះករណីកម្រដែលសហគមន៍វិលទៅរកការបន្ទោរបង់ពាសវាលពាសកាលឡើងវិញ អាចខុសពីការឆ្លើយតបចំពោះប្រជាជន ១-២ គ្រួសារដែលគ្មានគម្របបង្គន់ការពាររុយចូល។ ដូចគ្នានេះដែរ អាចមានការឆ្លើយតបជាឥរិយាបថ ប្រសិនបើមានហេដ្ឋារចនាសម្ព័ន្ធក្នុងសហគមន៍មួយ ប៉ុន្តែគ្មានការប្រើប្រាស់។ មួយវិញទៀត ប្រហែលជាត្រូវមានការឆ្លើយតបទៅតាមចំណុចដៅ ប្រសិនបើ ការភ្លាំងភ្លាត់កើតឡើងដោយសារបង្គន់ត្រូវបានបំផ្លាញដោយព្យុះស៊ីក្លូន។ គំនិតទាំងនេះ ត្រូវបានស្វែងយល់បន្ថែមក្នុងផ្នែកស្ដីពី "ការដោះស្រាយការភ្លាំងភ្លាត់៖ គំនិតពីមូលដ្ឋាន"។

*រូប ១ ៖ គំរូនៃការភ្លាំងភ្លាត់ក្នុងសង្វាក់មួយ*




## តើកត្តាអ្វីខ្លះរួមចំណែកបង្កការភ្លាំងភ្លាត់?

រូប ២ បង្ហាញថាមានមូលហេតុជាច្រើនដែលបង្កជាការភ្លាំងភ្លាត់ ហើយកត្តាបង្កអាចត្រូវបានបែងចែកជាប្រភេទតាមវិធីផ្សេងៗ (Tyndale-Biscoe et al. 2013; Jerneck et al. 2016)។ សម្រាប់ឯកសារទី ១៥ នេះ កត្តាបង្កការភ្លាំងភ្លាត់ត្រូវបានបែងចែកជា ៥ ប្រភេទពាក់ព័ន្ធគ្នា៖ កត្តាបច្ចេកវិទ្យា កត្តាឥរិយាបថ កត្តាពាក់ព័ន្ធនឹងភាពក្រីក្រ និងភាពងាយរងគ្រោះ និងកត្តាខាងក្រៅ (រូប ៣)។ កត្តារួមចំណែកបង្កការភ្លាំងភ្លាត់ ក៏ត្រូវបានចងក្រងក្នុងឯកសារផ្សេងទៀតផងដែរ។ តារាង ១ រៀបរាប់សង្ខេបពីកត្តានីមួយៗ និងផ្ដល់ទំនាក់ទំនងទៅនឹងឧទាហរណ៍ករណីពីមូលដ្ឋាន។

*រូប ២ ៖ មូលហេតុដែលបង្កជាការភ្លាំងភ្លាត់*




សម្គាល់ ៖ ការបង្ហាញជារូបភាពនេះគឺមិនគ្រប់ជ្រុងជ្រោយទេ។

គួរកត់សម្គាល់ថា ទំនាក់ទំនងនៃកត្តាបង្កការភ្លាំងភ្លាត់មានន័យថា មានភាពត្រួតគ្នារវាងបណ្ដុំកត្តានានា ហើយកត្តានីមួយៗអាចជះឥទ្ធិពលកាន់តែខ្លាំង។ ឧ. បញ្ហាភ្លាំងភ្លាត់ក្នុងតំបន់មួយដោយសារការបាក់ដី អាចមានទំហំធំធេង សម្រាប់គ្រួសារដែលមានមនុស្សចាស់ជាមេគ្រួសារ ព្រោះពួកគេមិនអាចសង់បង្គន់ឡើងវិញ ហើយចំណុចនេះនឹងបង្កជាការភ្លាំងភ្លាត់អចិន្ត្រៃយ៍។

> “មុខសញ្ញាគ្រោះថ្នាក់ពីធម្មជាតិកើតឡើងជាធម្មតា ជាពិសេសព្យុះទីហ្វុង។ សំខាន់បំផុត បង្គន់ជារចនាសម្ព័ន្ធ សំខាន់ដែលរងការបំផ្លិចបំផ្លាញ ទោះបីជាពេលខ្លះគេចាត់ទុកវាជារចនាសម្ព័ន្ធបន្ទាប់បន្សំក្ដី។ ប្រជាជនសង់បង្គន់ឡើងវិញយ៉ាងឆាប់រហ័ស ឬប្រើបង្គន់រួម នៅពេលមានបញ្ហានេះកើតឡើង”។
>
> *ការសម្ភាសអ្នកផ្ដល់ព័ត៌មានសំខាន់នៅតំបន់អាស៊ីអាគ្នេយ៍*

កត្តាឥរិយាបថជះឥទ្ធិពលយ៉ាងខ្លាំងលើកត្តាផ្សេងទៀតដែលបង្កជាការភ្លាំងភ្លាត់។ ខណៈដែលផ្នែកនេះពិនិត្យឡើងវិញលើបញ្ហាប្រឈមដែលតែងបង្កជាការភ្លាំងភ្លាត់នៃការបញ្ឈប់ ការបន្ទោរបង់ពាសវាលពាសកាល ទាំងស្រុងមិនមានន័យថា សុទ្ធតែមានការភ្លាំងភ្លាត់រហូតនោះទេ។

*រូប ៣ ៖ កត្តាអន្តរកម្មដែលបង្កជាការស្ទាក់ស្ទើរ*

## កត្តាបច្ចេកវិទ្យា

- គុណភាពបច្ចេកទេស និងភាពជាប់ធុន
- ការរចនា
- ភាពអាចប្រើប្រាស់បាន
- លទ្ធភាពទទួលបានសេវាផ្សេងទៀត



## កត្តាឥរិយាបថ

- កង្វះការផ្លាស់ប្តូរបទដ្ឋានសង្គម
- លទ្ធភាពខុសគ្នាក្នុងការប្រើប្រាស់បង្គន់អនាម័យ
- ជំនឿពាក់ព័ន្ធនឹងលាមកកុមារ
- ការធ្វើការឆ្ងាយពីផ្ទះ



## កត្តាខាងក្រៅ

- ប្រជាជនចំណូលស្រុក
- វិបត្តិអាកាសធាតុ ឬ វិបត្តិភូមិសាស្ត្រ



## កត្តាពាក់ព័ន្ធនឹងភាពក្រីក្រ និងភាពងាយរងគ្រោះ

- ភាពក្រីក្រ និងភាពងាយរងគ្រោះពង្រីកកត្តាបង្កការភ្លាំងភ្លាត់ដែលមានស្រាប់
- គុណភាពទាបពីដំបូង និងចំណាយលើការសង់ឡើងវិញ
- ភាពអាចប្រើប្រាស់បាន
- ភាពមិនអាចទទួលយកបាននៃការប្រើបង្គន់រួម



*តារាង ១ ៖ កត្តាបង្កការភ្លាំងភ្លាត់*

ប្រភព ៖ តារាងនេះផ្អែកតាមឯកសារយោងដូចតទៅ ៖ Cavill et al. 2015; Cavill et al. 2018; al.2017; Jacob 2018; Jerneck et al. 2016; Kohlitz et al. 2019; Ngwale and DeGabriele Robinson et al. 2016; Russpatrick et al. 2017; SNV Tanzania 2019; Thomas 2016; 2018; Wamera 2016; Wilbur and Jones 2014; WSSCC 2019; WSP-UNICEF 2015[3] ។

**កត្តាបង្កការភ្លាំងភ្លាត់**

**កត្តាបង្ការ**

**គុណភាពបច្ចេកទេស និងភាពជាប់ធន់**

- គុណភាពបច្ចេកទេស និងភាពជាប់ធន់របស់បង្គន់ដែលបានសង់ ដោយប្រើប្រាស់ជំនាញ និង ពាសវាលពាសកាលទាំងស្រុង ត្រូវបានកំណត់ជាកត្តាបង្កការភ្លាំងភ្លាត់ក្នុងបរិបទភាគច្រើន។
- កង្វះចំណេះដឹង និងជំនាញរបស់សិប្បករ និងជាងសំណង់ក្នុងមូលដ្ឋាន អាចជះឥទ្ធិពលលើ ការបាក់ដី ឬដីសំបូរថ្ម។
- កិច្ចខិតខំប្រឹងប្រែង និងចំណាយលើការសង់បង្គន់ឡើងវិញជាច្រើនដង អាចធ្វើឱ្យអស់ទឹកចិត្ត
- គួរកត់សម្គាល់ថា ក្នុងករណីមានការបញ្ច្រាបឥរិយាបថបញ្ឈប់ការបន្ទោរបង់ពាសវាលពាស បាក់រលំបង្គន់ ឬការជន់លិចរណ្ដៅបង្គន់ មានលក្ខណៈបណ្ដោះអាសន្ន។ ហេដ្ឋារចនាសម្ព័ន្ធ ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុងឡើងវិញ។

**ការរចនា**

- ការរចនាបង្គន់ និងកម្រិតដែលការរចនានោះបំពេញចិត្តរបស់អ្នកប្រើប្រាស់បង្កផលប៉ះពាល់ បង់ពាសវាលពាសកាលទាំងស្រុង ឬទេ។

**ភាពអាចប្រើប្រាស់បាន**

- មានការភ្លាំងភ្លាត់ក្នុងគ្រួសារ ឬសហគមន៍ដែលបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំង ឧបសគ្គរូបវន្តក្នុងការប្រើប្រាស់បង្គន់។

**លទ្ធភាពទទួលបានសេវាផ្សេងទៀត**

- ការភ្លាំងភ្លាត់អាចកើតឡើងនៅពេលដែលការរក្សានិរន្តរភាពនៃការបញ្ឈប់ការបន្ទោរបង់ពាស អ្នកប្រើប្រាស់ ព្រមទាំងលទ្ធភាពទទួលបានសេវាផ្សេងទៀតដូចជា ទឹកសម្រាប់លាងសម្អាត
- ប្រសិនបើកង្វះជម្រើសគ្រប់គ្រងកាកសំណល់លាមកដែលមានតម្លៃសមរម្យ ធ្វើឱ្យគេមិនអាច បន្ទោរបង់ពាសវាលពាសកាលដើម្បីឱ្យរណ្ដៅបង្គន់ប្រើបានយូរ ឬនៅពេលដែលរណ្ដៅបង្គន់

[3] គួរកត់សម្គាល់ថា ឯកសារទាំងនេះគឺមិនទាន់អស់នោះទេ និងមិនសុទ្ធតែលើកឡើងពីការភ្លាំងភ្លាត់ឡើយ

[4] ចំណាំ ៖ ឧទាហរណ៍ ៦ នៃកម្មវិធីដែលលើកឡើងពីគំរូផ្សេងៗនៃការភ្លាំងភ្លាត់ និងកត្តាបង្ក មានបង្ហាញក្នុង

Chambers and Myers 2016; Cole 2013; Gibson et al. 2018; Greaves 2016; House et 2017; Mukherjee, 2011; Odagiri et al. 2017; Orgill-Meyer et al. 2019; Pasteur 2012; Tyndale-Biscoe et al. 2013; UN-Habitat 2017; UNICEF 2014, 2016, 2017; USAID 2017,

| | ឧទាហរណ៍ករណីពាក់ព័ន្ធ[4] |
|---|---|
| **ភ្លាំងភ្លាត់** | |
| សម្ភារៈដែលមានក្នុងមូលដ្ឋាន ក្នុងពេលជំរុញទៅរកការបញ្ឈប់ ការបន្ទោរបង់<br>ភាពជាប់ធនរបស់បង្គន់ ជាពិសេសនៅពេលប្រឈមនឹងស្ថានភាពលំបាក ដូចជា<br>និងបង្កការភ្លាំងភ្លាត់ជារៀងរហូត។<br>កាលទាំងស្រុង និងមានការគាំទ្រពីបទដ្ឋានសង្គម ការភ្លាំងភ្លាត់ដោយសារការ ដែលបាត់បង់ ត្រូវបានជំនួសយ៉ាងឆាប់រហ័សដើម្បីទទួលបានស្ថានភាពបញ្ឈប់ | ទី ១<br>ទី ២<br>ទី ៦ |
| ថាតើការភ្លាំងភ្លាត់កើតឡើងបន្ទាប់ពីការជំរុញដំបូងទៅរកការបញ្ឈប់ការបន្ទោរ | ទី ២ |
| ស្រុងនៅពេលដែលមនុស្សចាស់ ឬជនពិការ ឬស្ត្រីមានផ្ទៃពោះប្រឈម នឹង | ទី ២<br>ទី ៣ |
| វាលពាសកាលទាំងស្រុង ផ្អែកលើវត្តមានហេដ្ឋារចនាសម្ព័ន្ធ និងឥរិយាបថរបស់ ដៃ ចាក់ទឹកបង្គន់ ឬលាងសម្អាតគូទ។<br>បូមសម្អាតរណ្ដៅបង្គន់ដែលពេញបាន សមាជិកគ្រួសារមួយចំនួនអាចវិលទៅ ពេញ គ្រួសារទាំងមូលនឹងវិលទៅបន្ទោរបង់ពាសវាលពាសកាលឡើងវិញ។ | |

ប៉ុន្តែឯកសារនីមួយៗមានការពិភាក្សាទូទៅលើប្រធានបទពាក់ព័ន្ធ។
ផ្នែកទី ៣ "ការដោះស្រាយការភ្លាំងភ្លាត់ ៖ គំនិតពីមូលដ្ឋាន"។

**កត្តា**

### កង្វះការផ្លាស់ប្តូរបទដ្ឋានសង្គម

- ក្នុងករណីដែលអន្តរាគមន៍មិនអាចផ្លាស់ប្តូរបទដ្ឋានសង្គមបាន និងមើលឃើញពីកង្វះការទទួល អនុលោមតាមពីដំបូង ប៉ុន្តែគ្រួសារខ្លះ ឬទាំងអស់មិនសូវមានភាពជឿជាក់ក្នុងការបន្តប្រើប្រាស់
- កង្វះការផ្លាស់ប្តូរបទដ្ឋានសង្គម បានជំរុញការប្រើប្រាស់បង្គន់ដោយផ្នែក នៅពេលសមាជិក ដូច្នេះបាននៅពេលខ្លះ។
- ជាញឹកញាប់ ការភ្លាំងភ្លាត់បណ្តាលមកពីកង្វះជំនួយលើការតាមដានបន្ត នៅពេលសហគមន៍ ឥរិយាបថ ការផ្លាស់ប្តូរបទដ្ឋានសង្គមជារួម និងផ្តល់ការកំណត់រកបញ្ហាទានពេលវេលា។

### លទ្ធភាពខុសគ្នាក្នុងការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធ

- ការភ្លាំងភ្លាត់អាចបណ្តាលមកពីបទដ្ឋានសង្គមក្នុងគ្រួសារ ដែលរួមចំណែកបង្កជាលទ្ធភាពខុស បង្គន់រួមជាមួយស្ត្រី បុរស ឬស្ត្រីដែលមិនប្រើបង្គន់រួមជាមួយសាច់ថ្លៃ ឬស្ត្រីដែលមិនប្រើបង្គន់
- ការស្រាវជ្រាវថ្មីៗ ដោយ GSF ក្នុងប្រទេសម៉ាឡាវី បានរកឃើញការភ្លាំងភ្លាត់ប្រភេទនេះ ជា ថាមានត្រឹមតែ ៦០% (WSSCC 2019)។

### ជំនឿពាក់ព័ន្ធនឹងលាមកកុមារ

- ការគ្រប់គ្រងលាមកកុមារមិនបានសមស្របពាក់ព័ន្ធនឹងការយល់ថា លាមកកុមារមិនបង្កគ្រោះ ធ្លាប់សម្រេចបានការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុង ច្រើនបណ្តាលមកពី កុមារដោយគ្មានអនាម័យ។
- ការសិក្សាមួយដោយ UNICEF និង WSP ក្នុងបណ្តាប្រទេសដែលបានត្រួតពិនិត្យ រកឃើញថា លាមកកុមារដោយគ្មានសុវត្ថិភាព។ ការសិក្សានិរន្តរភាពមួយក្នុងប្រទេសម៉ាដាហ្គាស្កា រកឃើញ ដល់កម្រិតមួយដែលទាបជាងកម្រិតដើមគ្រា[5]។

### ការធ្វើការឆ្ងាយពីផ្ទះ

- ការភ្លាំងភ្លាត់អាចកើនឡើងនៅពេលមនុស្សដែលធ្វើការឆ្ងាយពីផ្ទះនៅពេលថ្ងៃ គ្មានភាពងាយ
- កត្តានេះក៏សំខាន់ផងដែរ ក្នុងករណីដែលពលករបណ្តោះអាសន្នធ្វើការឆ្ងាយពីផ្ទះរហូតដល់ ទាំងស្រុង អាចធ្វើបំលាស់ទីនៅចន្លោះតំបន់ខ្ពង់រាប និងវាលទំនាបតាមរដូវកាល។ បញ្ហាគឺថា នៅពេលពួកគេចាកចេញពីលំនៅដ្ឋានអចិន្ត្រៃយ៍ ឬទេ[7]។

**កត្តាពាក់ព័ន្ធនឹងភាពក្រីក្រ**

---

[5]មានការលើកឡើងថា គ្មានការបោះចោលលាមកកុមារឱ្យបានសមស្របទេ និងធ្វើឱ្យមានការប៉ាន់ស្មានខ្ពស់

[6]ការសម្ភាសអ្នកផ្តល់ព័ត៌មានសំខាន់នៅអាស៊ីខាងត្បូង

[7]ការសម្ភាសអ្នកផ្តល់ព័ត៌មានសំខាន់នៅអាស៊ីខាងត្បូង

| ឥរិយាបថ | |
|---|---|
| យកការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុង គ្រួសារនឹងបង្គន់ទេ នៅពេលលែងមានសម្ពាធ។<br>គ្រួសារខ្លះជឿថា ពួកគេនៅតែអាចបន្ទោរបង់ពាសវាលពាសកាល ឬអាចធ្វើ<br>សម្រេចបានការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុងដើម្បីពង្រឹង | ទី ២<br>ទី ៦ |
| គ្នាក្នុងការទទួលបានហេដ្ឋារចនាសម្ព័ន្ធ។ ឧទាហរណ៍រួមមាន បុរសដែលមិនប្រើគ្រួសារនៅពេលមករដូវ។<br>ពិសេសពាក់ព័ន្ធនឹងលទ្ធភាពប្រើប្រាស់បង្គន់របស់ក្មេងស្រីដែលគេរកឃើញ | ទី ២ |
| ថ្នាក់។ ការបន្ទោរបង់ពាសវាលពាសកាលដែលគេរកឃើញក្នុងសហគមន៍ដែលការប្រើប្រាស់បង្គន់មិនជាប់លាប់ដោយកុមារតូចៗ និងការបោះចោលលាមក<br>គ្រួសារចំនួន ១១%-៦៩% ដែលមានអនាម័យល្អប្រសើរ នៅតែបោះចោលថា ក្រោយរយៈពេល ៣ ឆ្នាំ ការបោះចោលលាមកកុមារដោយសុវត្ថិភាព បានធ្លាក់ | ទី ២<br>ទី ៩ |
| ស្រួលក្នុងការប្រើបង្គន់ និងវិលទៅរកការបន្ទោរបង់ពាសវាលពាសកាលវិញ។<br>៦ ខែ[6] ឬក៏សហគមន៍ទាំងមូលដែលបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាល<br>តើមានការរក្សាឥរិយាបថបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំង ស្រុង | |
| **និងភាពងាយរងគ្រោះ** | |

ជ្រុលនៅពេលបញ្ជាក់ការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុង។

**ភាពក្រីក្រ និងភាពងាយរងគ្រោះបង្កើនកត្តាបង្កការភ្លាំងភ្លាត់ដែលមានស្រាប់**

- សមាជិកសហគមន៍ដែលក្រីក្របំផុត ច្រើនតែជាអ្នកដែលងាយភ្លាំងភ្លាត់។ ក្រុមជួបការលំបាក បង់ពាសវាលពាសកាលទាំងស្រុងដោយសារហេតុផលជាច្រើន។ លទ្ធផលនៃការអង្កេតរបស់ រារាំងការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុង និងបង្កជាការភ្លាំងភ្លាត់យ៉ាងឆាប់
- ភាពក្រីក្រ និងភាពងាយរងគ្រោះ មិនត្រឹមតែជាកត្តាបង្កការភ្លាំងភ្លាត់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំង បញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុងពឹងផ្អែកលើលទ្ធភាពលែលកសេវាផ្សេង បង្គន់ ឬកង្វះគុណភាពនៅពេលសង់ដំបូង)។

**គុណភាពទាបពីដំបូង និងចំណាយលើការសង់ឡើងវិញ**

- នៅពេលពិចារណាពីគុណភាពបច្ចេកទេស និងភាពជាប់ធន់របស់បង្គន់ ខណៈដែលកត្តាទាំង កម្រិតណាមួយ គ្រួសារក្រីក្របំផុតមានលទ្ធភាពតិចបំផុតក្នុងការទិញហេដ្ឋារចនាសម្ព័ន្ធដែលមាន
- ធៀបនឹងគ្រួសារស្តុកស្តម្ភ គ្រួសារក្រីក្រចំណាយច្រើនលើការជួសជុល (ធៀបនឹងចំណាយដំបូងលើ ការភ្លាំងភ្លាត់នៃការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុងអាចកើតឡើងនៅពេលដែល

**ភាពអាចប្រើប្រាស់បាន**

- មនុស្សចាស់ និងជនពិការ អាចប្រឈមនឹងឧបសគ្គរូបវន្តក្នុងការប្រើប្រាស់បង្គន់ និងវិលទៅរកការ

**ភាពមិនអាចទទួលយកបាននៃការប្រើបង្គន់រួម**

ក្នុងប្រទេសជាច្រើន ដែលផ្តោតសំខាន់លើការលុបបំបាត់ការបន្ទោរបង់ពាសវាលពាសកាលទាំង បន្ទោរបង់ពាសវាលពាសកាលទាំងស្រុង (Bevan and Thomas, 2013) និងច្រើនតែត្រូវបានលើក ក្នុងបណ្តាប្រទេសជាច្រើន (អេត្យូពី ឥណ្ឌូនេស៊ី កេនយ៉ា ហ្វីលីពីន សេរ៉ាឡេអូន អ៊ុយហ្គង់ដា) រក ថា បង្គន់រួមបំពេញលក្ខណៈវិនិច្ឆ័យនៃការគ្រប់គ្រងអនាម័យដោយសុវត្ថិភាព ឬមូលដ្ឋានក្នុងចំណុច

**កត្តា**

**ប្រជាជនចំណូលស្រុក**

- សហគមន៍ផ្លាស់ទីទៅមក ហើយបុគ្គល ឬក្រុមនានាបានចូលមក ឬចាកចេញទៅវិញដោយ ដែលបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុង អាចរំខានដល់ការបញ្ឈប់ការបន្ទោរ ភ្លាំងភ្លាត់។ ទំហំ និងភាពអាចព្យាករណ៍បាននៃចលនាប្រជាជន ជះឥទ្ធិពលលើផលប៉ះពាល់
- ទំហំតូចដូចជា ការបង្កើតគ្រួសារថ្មីតាមរយៈអាពាហ៍ពិពាហ៍ និងអ្នកធ្វើដំណើរដែលឈប់
- ទំហំធំ ប៉ុន្តែអាចព្យាករណ៍បានដូចជា ទីផ្សារ ពិធីបុណ្យ ឬការប្រារព្ធពិធីសាសនា
- បំលាស់ទីប្រជាជនភ្លាមៗ និងទ្រង់ទ្រាយធំដោយសាការបាត់បង់ទីលំនៅក្នុងប្រទេសដែល

**វិបត្តិអាកាសធាតុ ឬវិបត្តិភូមិសាស្ត្រ**

- កត្តាខាងក្រៅផ្សេងទៀត រួមមាន វិបត្តិអាកាសធាតុ ដូចជា ទឹកជំនន់ និងព្យុះទីហ្វុង (ឧ.Aroroy, ឬបន្ទុះភ្នំភ្លើង ដែលអាចធ្វើឱ្យមានការភ្លាំងភ្លាត់នៃការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាល

---

[8] ការសម្ភាសអ្នកផ្តល់ព័ត៌មានសំខាន់ជាសកល

[9] Draft report `Coping strategies on damaged toilet facilities: The case of Aroroy, Masbate´, UNICEF,

[10] ការសម្ភាសអ្នកផ្តល់ព័ត៌មានសំខាន់ក្នុងប្រទេសនេប៉ាល់

| | |
|---|---|
| ឬងាយរងគ្រោះប្រហែលជាមិនអាចសម្រេចបាន ឬរក្សាការបញ្ឈប់ការបន្ទោរ GSF ក្នុងប្រទេសនានា គូសបញ្ជាក់ថាកង្វះការរួមបញ្ចូលជាឧបសគ្គដ៏ធំដែលរហ័ស[៨]។<br>រួមផ្សំជាមួយកត្តាបង្កការភ្លាំងភ្លាត់ផ្សេងទៀតផងដែរ (ឧ. ក្នុងករណីដែលការទៀតដូចជា ទឹកសម្រាប់ចាក់បង្គន់ និងលាងសម្អាតដៃ ឬសេវាបូមសម្អាតរណ្ដៅ | ទី ៦ |
| នេះអាចប៉ះពាល់ដល់ក្រុមសង្គមសេដ្ឋកិច្ចទាំងអស់ក្នុងសហគមន៍ជនបទនៅគុណភាពល្អ ពោលគឺបង្គន់ទាំងនោះងាយបាក់រលំ និងបង្កជាការភ្លាំងភ្លាត់។<br>ការសាងសង់) ដោយសារតែគុណភាពទាបនៅពេលសង់ដំបូង (UNICEF 2014)។ គ្រួសារក្រីក្រលែងមានលទ្ធភាពជួសជុល បូមសម្អាត ឬផ្លាស់ហេដ្ឋារចនាសម្ព័ន្ធថ្មី។ | ទី ២ |
| បន្ទោរបង់ពាសវាលពាសកាលដោយផ្ទាល់ ឬត្រូវប្រើជម្រើសដែលគ្មានអនាម័យ។ | ទី ៣ |
| ស្រង ការប្រើបង្គន់រួមជាជម្រើសដែលគេទទួលយកសម្រាប់ការបញ្ឈប់ការឡើងសម្រាប់អ្នកដែលមិនអាចសង់បង្គន់ដោយខ្លួនឯងបាន។ ប៉ុន្តែការសិក្សាឃើញថា ការប្រើបង្គន់រួមជាកត្តាមួយដែលបង្កជាការភ្លាំងភ្លាត់។ គេមិនចាត់ទុកដៅទី ៦.២ នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទេ។ | ទី ២ |
| **ខាងក្រៅ** | |
| សារមូលហេតុផ្សេងៗ។ វត្តមានអ្នកបន្ទោរបង់ពាសវាលពាសកាលនៅក្នុងតំបន់បង់ពាសវាលពាសកាលទាំងស្រុងជាបណ្ដោះអាសន្ន ឬយូរអង្វែង និងបង្កជាការរបស់វា ៖<br>សម្រាកតាមមហាវិថី<br>បណ្ដាលមកពីជម្លោះ ឬគ្រោះមហន្តរាយធម្មជាតិ។ | ទី ៥ |
| Masbate ក្នុងប្រទេសហ្វីលីពីន ២០១៦[9] ) ឬវិបត្តិភូមិសាស្ត្រដូចជា គ្រោះ រញ្ជួយដីទាំងស្រុង (ឧ.គ្រោះរញ្ជួយដីក្នុងប្រទេសនេប៉ាល់ ២០១៥[10] )។ | |

2016.

ចាំបាច់ត្រូវមានការស្រាវជ្រាវបន្ថែម៖

## ការភ្លាំងភ្លាត់ក្នុងគ្រួសារ

មានភស្តុតាងជាច្រើនបង្ហាញថា ឌីណាមិកសង្គមក្នុងគ្រួសារធ្វើឱ្យមានលទ្ធភាពខុសៗគ្នាក្នុងការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធមានស្រាប់។ ក្នុងករណីខ្លះ មានការយល់ដឹងខ្លះពីចំណុចនេះ ដូចជាជំនឿបែបប្រពៃណីជុំវិញការមករដូវឬការប្រើបង្គន់រួមជាមួយសាច់ថ្លៃ (Chambers and Myers 2016)។ ក្នុងករណីផ្សេងទៀត មានការយល់ដឹងថ្មីៗដែលត្រូវលើកមកលាតត្រដាង ដូចជា មូលហេតុដែលក្មេងស្រីមិនសូវអាចប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធក្នុងគ្រួសារ (WSSCC 2019)។

ចាំបាច់ត្រូវមានការស្រាវជ្រាវជាច្រើន និងការចែករំលែកមេរៀនស្ដីពីរបៀបកំណត់រក និងរៀបរាប់ពីការភ្លាំងភ្លាត់ក្នុងគ្រួសារ បូករួមនឹងការចងក្រងឯកសារស្ដីពីវិធីសាស្ត្រផ្លាស់ប្ដូរឥរិយាបថដែលមានប្រសិទ្ធភាព ដើម្បីលើកឡើងពីបទដ្ឋានសង្គមដែលបង្កជាការភ្លាំងភ្លាត់ក្នុងបរិបទទាំងនេះ។

## ការរក្សានិរន្តរភាពនៃការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុងក្នុងចំណោមគ្រួសារក្រីក្របំផុត

វគ្គតាមប្រធានបទក្នុងសន្និសីទ AfricaSan5 សន្និដ្ឋានថា ការផ្ដោតការយកចិត្តទុកដាក់លើមនុស្សគ្រប់រូប មិនកើតឡើងដោយឯកឯងនោះទេ ប៉ុន្តែចាំបាច់ត្រូវមានយុទ្ធសាស្ត្រច្បាស់លាស់សម្រាប់ការផ្ដោតលើគ្រួសារក្រីក្រ និងងាយរងគ្រោះបំផុត ដើម្បីធានាថា មនុស្សគ្រប់រូបក្នុងសហគមន៍អាចប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធអនាម័យដែលអាចទទួលយកបាន និងបំពេញតម្រូវការ និងការចង់បានជាដរាប ដោយមិនគិតពីសមត្ថភាពបង់ប្រាក់ (AMCOM នឹងបោះពុម្ពផ្សាយឆាប់ៗនេះ)។ ប្រទេស និងអង្គការជាច្រើន កំពុងចាប់ផ្ដើមស្វែងរកដំណោះស្រាយក្រោយការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុង ដែលឧបត្ថម្ភថវិកា ឬសម្ភារៈកាន់តែច្រើនដល់គ្រួសារក្រីក្របំផុត ដែលសម្រេចបានឥរិយាបថបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុង ទន្ទឹមនឹងការបន្តអនុវត្តវិធីសាស្ត្រដឹកនាំដោយសហគមន៍។ ឯកសារទី ១០ និងទី ១៣ នៃកម្រងឯកសារ "ព្រំដែននៃកម្មវិធីសហគមន៍ដឹកនាំអនាម័យទាំងស្រុង" (House et al. 2017; Kohlitz et al. 2019) ផ្ដល់ការពិភាក្សាទូលំទូលាយស្ដីពីយន្តការគាំទ្រនានា។ ជារួម គួរចងក្រង និងចែករំលែកមេរៀនបន្ថែម ស្ដីពីរបៀបដែលវិធីសាស្ត្រនានាអាចផ្ដោតសំខាន់លើការភ្លាំងភ្លាត់។

## ការដោះស្រាយការខ្លាំងខ្លាត់ ៖ គំនិតពីមូលដ្ឋាន

ផ្អែកតាមក្របខណ្ឌដែលបានប្រើប្រាស់កន្លងមក ដើម្បីពិនិត្យមើលគំរូនៃការភ្លាំងភ្លាត់ ចាំបាច់ត្រូវមានការឆ្លើយតបផ្សេងៗ ទៅតាមគំរូដែលបានកត់សម្គាល់។ អ្នកអនុវត្តន៍ WASH/CLTS និងក្រុមសហគមន៍អាចវាយតម្លៃគំរូនេះ ដោយពិនិត្យមើលផ្នែកដែលសហគមន៍របស់ខ្លួនបរាជ័យនៅចំណុចនោះក្នុងបណ្តុំសង្វាក់នានា (រូប ៤)។ ការភ្លាំងភ្លាត់ដែលមានទ្រង់ទ្រាយធំ និងធ្ងន់ធ្ងរ ទាមទារការឆ្លើយតបទូទាំងសហគមន៍ ចំណែកករណីជាក់លាក់នៃការភ្លាំងភ្លាត់ដែលពាក់ព័ន្ធនឹងបញ្ហាប្រឈមក្នុងគ្រួសារនីមួយៗ អាចដោះស្រាយបានដោយប្រើវិធីសាស្រ្តផ្តោតជាក់លាក់។ ក្នុងករណីជាច្រើនគំរូនៃការភ្លាំងភ្លាត់នឹងស្ថិតនៅទីតាំងណាមួយនៅចន្លោះចំណុចពីរ ដែលបង្ហាញថាអាចត្រូវការការឆ្លើយតបចម្រុះ។ សម្រាប់ករណីសិក្សានីមួយៗ គំរូនៃការភ្លាំងភ្លាត់ត្រូវបានវាយតម្លៃជាសង្វាក់ និងសម្គាល់ដោយផ្កាយមួយ ដើម្បីបង្ហាញពីដំណើរការក្នុងការអនុវត្តជាក់ស្តែង។

*រូប ៤ ៖ គំរូនៃការឆ្លើយតបនឹងការភ្លាំងភ្លាត់*




ឧទាហរណ៍នៃការឆ្លើយតប

- ការផ្លាស់ប្តូរឥរិយាបថតាមរយៈការប្រាស្រ័យទាក់ទងក្នុងសហគមន៍
- ការបំផុសឡើងវិញ
- កិច្ចសន្ទនាក្នុងសហគមន៍

ឧទាហរណ៍នៃការឆ្លើយតប៖

- ក្រុមគាំទ្រ
- ជំនួយបច្ចេកទេស
- ការផ្តល់ជំនួយដល់ក្រុមគោលដៅ

ការពិនិត្យឡើងវិញនេះ ខិតខំកំណត់រកឧទាហរណ៍ស្តីពីរបៀបដោះស្រាយការភ្លាំងភ្លាត់ក្នុងបរិបទផ្សេងៗ ប៉ុន្តែគួរកត់សម្គាល់ថា មានការលំបាកក្នុងការរកបានករណីជាក់លាក់ ឬឧទាហរណ៍តាមមូលដ្ឋានស្តីពីវិធីសាស្ត្រស្តារការភ្លាំងភ្លាត់។

## ១.ជំនួយបច្ចេកទេសសម្រាប់ដោះស្រាយកត្តាបច្ចេកវិទ្យាដែលបង្កជាការភ្លាំងភ្លាត់

| **កត្តាបង្កការភ្លាំងភ្លាត់ដែលបានលើកឡើង៖** | |
|---|---|
| **កត្តាបច្ចេកវិទ្យា** | • គុណភាពផ្នែកបច្ចេកទេស និងភាពជាប់ធន់ នៃហេដ្ឋារចនាសម្ព័ន្ធដែលបានសង់ដោយប្រើសម្ភារៈក្នុងមូលដ្ឋាន |
| **កត្តាភាពក្រីក្រ និងភាពងាយរងគ្រោះ** | • គុណភាពទាបតាំងពីដំបូង<br>• ចំណាយលើការសង់ឡើងវិញ |

"ក្នុងប្រទេសឡាវ ការបន្ទោរបង់ពាសវាលពាសកាលក្នុងតំបន់មួយចំនួនមានចំនួន ៩០%។ ដូច្នេះប្រជាជនមិនសូវមានបទពិសោធន៍បច្ចេកទេសលើការសង់បង្គន់ទេ។ សំណង់មិនល្អសំដៅលើរណ្តៅបង្គន់ ដែលឆាប់ពេញដោយគ្មានការណែនាំបច្ចេកទេសចាំបាច់ ដើម្បីដោះស្រាយបញ្ហាទាំងនេះ"។
*ការសម្ភាសអ្នកផ្តល់ព័ត៌មានសំខាន់នៅអាស៊ី*

មានឧទាហរណ៍ជាច្រើនស្តីពីរបៀបដោះស្រាយកត្តាបង្កការភ្លាំងភ្លាត់ ដែលពាក់ព័ន្ធនឹងបច្ចេកវិទ្យា តាមរយៈការបង្កើនចំណេះដឹងនិងជំនាញបច្ចេកទេសរបស់សិប្បករជាងសំណង់អ្នកដឹកនាំ និងបុគ្គលិកសុខាភិបាល ក្នុងមូលដ្ឋាន"[11] ។

ប្រទេសកេនយ៉ា និងប្រទេសឥណ្ឌាសុទ្ធតែបានការកសាងសមត្ថភាពបច្ចេកទេស របស់សិប្បករ និងជាងសំណង់ក្នុងមូលដ្ឋានដើម្បីផ្តល់ការកែលម្អ និងដំណោះស្រាយជាប់ធន់ក្នុងការ "សង់បង្គន់ឡើងវិញឱ្យល្អជាងមុន" ទន្ទឹមនឹងការបន្តផ្តោតលើដំណោះស្រាយក្នុងមូលដ្ឋាន។ កម្មវិធីក្នុងសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោនិងប្រទេសវ៉ាន់ដា បានលើកកម្ពស់ការគាំទ្រផ្នែកបច្ចេកទេសដោយមិនផ្អែកលើទីផ្សារតាមរយៈ ការបណ្តុះបណ្តាលអ្នកដឹកនាំនិងបុគ្គលិកសុខាភិបាលឱ្យផ្តល់ដំបូន្មានមូលដ្ឋានស្តី




ការណែនាំរបស់អ្នកស្ម័គ្រចិត្ត សុខភាពសហគមន៍ និងអ្នកដែលមានទេពកោសល្យជាអ្នកដឹកនាំពីកំណើត ស្តីពីការជ្រើសរើសបង្គន់។ *ក្រេឌីត ៖ ក្រសួងសុខាភិបាលកេនយ៉ា។*

[11] ឧទាហរណ៍ផ្តល់ដោយអ្នកផ្តល់ព័ត៌មានសំខាន់ក្នុងតំបន់អាហ្វ្រិកភាគខាងលិច និងភាគកណ្តាល តំបន់អាស៊ី ប្រទេសឥណ្ឌា កេនយ៉ា នេប៉ាល់ និងហ្វីលីពីន។

ពីរបៀបជីករណ្តៅដែលមិនងាយបាក់ និងការពារឈើមិនឱ្យកណ្ដៀរស៊ី។ ក្នុងប្រទេសហ្វីលីពីនគ្រួសារដែលប្រើបង្គន់រួមពីដំបូងរួចឈប់ប្រើបង្គន់រួមបណ្តើរៗ ទទួលបានការណែនាំ ស្តីពីជម្រើសសង់បង្គន់ដែលចំណាយតិច។ ក្រសួងសុខាភិបាលកេនយ៉ាគ្រោងនឹងកែសម្រួលសៀវភៅណែនាំបច្ចេកទេស សម្រាប់ចែកជូនមន្ត្រីសុខភាពសាធារណៈ និងបុគ្គលិកសុខភាពសហគមន៍ ដែលផ្តោតសំខាន់តែលើការសង់បង្គន់ទំនើប[12] និងបានបង្កើតឯកសារជំនួយដើម្បីផ្តល់លទ្ធភាពឱ្យអ្នកជំនាញសុខភាពសហគមន៍ អ្នកស្ម័គ្រចិត្ត និងអ្នកដែលមានទេពកោសល្យជាអ្នកដឹកនាំពីកំណើត ផ្តល់ការណែនាំដល់គ្រួសារស្តីពីការបង្កើនគុណភាពរបស់បង្គន់ដែលបានសង់ ទៅតាមតម្លៃដែលផ្តល់ជូន តម្រូវការ និងការចង់បានរបស់ពួកគេ (Coombes 2016)។

## ករណីសិក្សា៖ ការបណ្តុះបណ្តាលសិប្បករស្តីពីការ "សង់បង្គន់ឡើងវិញឱ្យល្អជាងមុន" ក្នុងប្រទេសកេនយ៉ា[13]

*រូប ៥ ៖ គំរូនៃការភ្លាំងភ្លាត់ដែលលេចឡើងក្នុងឧទាហរណ៍ករណី*




[12]ការសម្ភាសអ្នកផ្តល់ព័ត៌មានសំខាន់ក្នុងប្រទេសកេនយ៉ា
[13]ការសម្ភាសអ្នកផ្តល់ព័ត៌មានសំខាន់ក្នុងប្រទេសកេនយ៉ា

មិនខុសពីប្រទេសជាច្រើនផ្សេងទៀតដែរ បង្គន់ខ្លះនៅទីជនបទ ក្នុងប្រទេសកេនយ៉ា ត្រូវបានសង់ឡើងដោយប្រើសម្ភារៈក្នុងមូលដ្ឋា នដែលមិនជាប់ធន់ និងងាយដួលរលំដោយសារភ្លៀង ឬកណ្តៀរស៊ី។

ការភ្លាំងភ្លាត់នេះស្ទើរតែមានលក្ខណៈបណ្តោះអាសន្នជានិច្ច ខណៈដែលគ្រួសារសង់បង្គន់ផ្ទាល់ខ្លួនឡើងវិញ។ ប្រជាជនប្រើប្រាស់បង្គន់រួមជាមួយអ្នកជិតខាងជាបណ្តោះអាសន្ន ឬអនុវត្ត "វិធីសាស្ត្រសត្វឆ្មា" (សំដៅលើការបន្ទោរបង់ដោយកាប់រណ្តៅជុះ)។ ជាទូទៅ គ្រួសារក្នុងស្ថានភាពនេះស្វែងរកការណែនាំផ្នែកបច្ចេកទេសពីសិប្បករក្នុងមូលដ្ឋាន ដើម្បីកែលម្អការរចនាបង្គន់របស់ខ្លួនឱ្យមានគុណភាពល្អ និងជាប់ធន់។

ក្នុងកម្មវិធី KSHIP[14] ដែលផ្តល់ជំនួយមូលនិធិដោយមូលនិធិអនាម័យសកល AMREF បានសហការជាមួយរដ្ឋាភិបាលជាតិ រដ្ឋាភិបាលមូលដ្ឋាននិងដៃគូអនាម័យ ដើម្បីបណ្តុះបណ្តាលសិប្បករមូលដ្ឋានតាមស្រុក ជាច្រើន ដូចជា Uashan Gishu, Busia, Narok, Kisii និង Muranga។ ការបណ្តុះបណ្តាលផ្តោតលើសហគមន៍ ដែលមានការធានាឥរិយាបថបញ្ឈប់ ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុងប៉ុន្តែមានបញ្ហាផ្នែកបច្ចេកទេស[15] ។

វិធីសាស្ត្រនេះប្រើប្រាស់ការរៀនសូត្រក្នុងចំណោមសិប្បករ ដើម្បីធានាការកសាងសមត្ថភាព និងជំនាញសមស្របទៅតាមបរិបទមូលដ្ឋាន ហើយសហគមន៍នៅតែមានសមត្ថភាព និងជំនាញទាំងនេះក្រោយការបញ្ចប់គម្រោង។

**ជំហាន ៖**

១. ការកំណត់អត្តសញ្ញាណសិប្បករដែលកំពុងធ្វើការក្នុងតំបន់នេះ ដូចជា ជាងផ្ទះ។
២. សិប្បករទទួលបានការបណ្តុះបណ្តាលជាក់ស្តែង ស្តីពីរបៀបដែលការកែសម្រួលតិចតួចលើការរចនាបង្គន់ និងការប្រើសម្ភារៈដែលរកបានពីមូលដ្ឋាន អាចបង្កើនភាពជាប់ធន់។
៣. ការបណ្តុះបណ្តាលរួមបញ្ចូលការណែនាំស្តីពីជម្រើសដែលចំណាយតិច និងរបៀបធ្វើការជាមួយគ្រួសារដើម្បីកំណត់យកលក្ខណៈនៃការរចនាដែលចាំបាច់ ឬចង់បាន ដោយផ្អែកតាមថវិការបស់ពួកគេ។
៤. ក្រោយការបណ្តុះបណ្តាល សិប្បករទទួលបានការគាំទ្រផ្នែកបច្ចេកទេស ពីនាយកដ្ឋានសុខភាពសាធារណៈ និងឧបករណ៍នានា ដូចជា ឯកសារជំនួយ។

---

[14]មូលនិធិអនាម័យសកល (GSF) កម្មវិធីលើកកម្ពស់អនាម័យនៅប្រទេសកេនយ៉ា (KSHIP) ដែលធ្វើប្រតិបត្តិការក្នុងអនុស្រុកចំនួន១១។

[15]KSHIP បានបណ្តុះបណ្តាលសិប្បករក្នុងតំបន់កម្មវិធីថ្មី ដើម្បីធានាថា គ្រួសារ សហគមន៍ និងសិប្បករទទួលបានចំណេះដឹងស្តីពីរបៀបសង់បង្គន់ដែលមានគុណភាពល្អបំផុតដោយប្រើសម្ភារៈក្នុងមូលដ្ឋាន និងចំណេះធ្វើ មុនពេល ឬភ្លាមៗបន្ទាប់ពីការបំផុស។

[16]គន្លឹះផ្តល់ដោយអ្នកផ្តល់ព័ត៌មានសំខាន់ក្នុងប្រទេសអេត្យូពី ឥណ្ឌា កេនយ៉ា នេប៉ាល់ ហ្វីលីពីន

**គន្លឹះ និងការណែនាំស្តីពីការផ្តល់ជំបូន្មានផ្នែកបច្ចេកទេសដើម្បីដោះស្រាយការភ្លាំងភ្លាត់[16]**

- រក្សាតុល្យភាព រវាងជំបូន្មានផ្នែកបច្ចេកទេសដើម្បីជាជំនួយដល់ការសម្រេចចិត្ត និង "ការសាងសង់ហួសកម្រិត" ដោយប្រើការរចនាដែលបានកំណត់។ គួរបន្តផ្តោតលើដំណោះស្រាយដែលផ្អែកតាមបរិបទមូលដ្ឋាន ដោយប្រើប្រាស់សម្ភារៈដែលរកបានក្នុងមូលដ្ឋាន និងកែសម្រួលមធ្យោបាយនានាដើម្បីបង្កើនភាពជាប់ធន់។
- សិប្បករក្នុងមូលដ្ឋាន និងសហគមន៍ សង់ផ្ទះដែលរឹងមាំទៅតាមបរិបទរបស់ខ្លួន និងគួរត្រូវបានលើកទឹកចិត្តឱ្យប្រើប្រាស់បច្ចេកទេសនេះសម្រាប់ការសង់បង្គន់។ ជំរុញការចូលរួមរបស់សហគមន៍ជាមុន ព្រោះពួកគេមានបទពិសោធន៍ក្នុងការសង់បង្គន់កន្លងមក និងគំនិតល្អៗស្តីពីការកែលម្អ ការចង់បាន ការរចនានិងការកែប្រែនានា និងសម្ភារៈជាជម្រើសដើម្បីទប់ស្កាត់ការភ្លាំងភ្លាត់ម្តងទៀត។
- ផ្តល់ជំនួយបច្ចេកទេសដល់ជាងសំណង់ និងសិប្បករ ដូចជា ជំនួយពីមន្ទីរសុខភាពសាធារណៈនៅថ្នាក់ស្រុក ឬមូលដ្ឋាន ដើម្បីធានាការបញ្ជូនករណីស្មុគស្មាញ និងផ្តល់ការណែនាំនានា។

## ២.រចនាសម្ព័ន្ធគាំទ្រសហគមន៍សម្រាប់បន្តផ្តល់ការគាំទ្រ និងការលើកទឹកចិត្ត

| **កត្តាបង្កការភ្លាំងភ្លាត់ដែលបានលើកឡើង៖** | |
|---|---|
| **កត្តាបច្ចេកវិទ្យា** | • គុណភាពផ្នែកបច្ចេកទេស និងភាពជាប់ធន់នៃហេដ្ឋារចនាសម្ព័ន្ធដែលបានសង់<br>• ការរចនា<br>• ភាពអាចប្រើប្រាស់បាន |
| **កត្តាឥរិយាបថ** | • កង្វះការផ្លាស់ប្តូរបទដ្ឋានសង្គម<br>• លទ្ធភាពខុសគ្នា ក្នុងការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធក្នុងគ្រួសារ<br>• ជំនឿពាក់ព័ន្ធនឹងលាមកកុមារ |

ជាញឹកញាប់ ការភ្លាំងភ្លាត់បណ្តាលមកពីកង្វះការគាំទ្រដល់ការតាមដានបន្តបន្ទាប់ពីសហគមន៍សម្រេចបានការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុង ដើម្បីពង្រឹងឥរិយាបថ ធ្វើឱ្យមានការផ្លាស់ប្តូរបទដ្ឋានសង្គម និងផ្តល់ការកំណត់រកបញ្ហាទាន់ពេលវេលា។ ក្រុមសកម្មភាពសហគមន៍ត្រូវបានបង្កើតឡើងតាមបណ្តាប្រទេសជាច្រើនដើម្បីបន្តផ្តល់ការគាំទ្រ និងការលើកទឹកចិត្តបន្ទាប់ពីការប្រកាសការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុង និងដោះស្រាយការភ្លាំងភ្លាត់ឱ្យបានឆាប់រហ័សបំផុត។ ឧទាហរណ៍នៃក្រុមទាំងនេះរួមមានក្រុមសកម្មភាព Jirani ក្នុងប្រទេសតង់ហ្សានី (Rieiro

2019) ក្រុមតាមដាន Mandona ក្នុងប្រទេសម៉ាដាហ្គាស្កា (England 2016) និងក្រុម WASHcoms ក្នុងប្រទេសនីហ្សេរីយ៉ា[17] ។

> "ការទទួលបានការគាំទ្រជាបន្តបន្ទាប់ ប្រៀបដូចជាការក្រើនរំលឹក រហូតដល់ការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុងក្លាយជាទម្លាប់"។
>
> *ការសម្ភាសអ្នកផ្ដល់ព័ត៌មានសំខាន់នៅតំបន់អាហ្វ្រិកខាងកើត*



ការបណ្ដុះបណ្ដាលបំប៉ន រវាងបុគ្គលិកសុខភាពម្នាក់ និងមេក្រុម Jirani ដើម្បីបង្កើនសុក្រឹតភាពទិន្នន័យ ដែលក្រុមនេះ បានបំពេញក្នុងសៀវភៅគោលបញ្ជីអនាម័យរបស់រដ្ឋាភិបាល។ *ក្រេឌីត ៖ SNV តង់ហ្សានី។*

## ករណីសិក្សា ៖ ការគាំទ្រដល់ការតាមដានបន្តដោយក្រុមអនាម័យ Jirani ក្រោយការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុង ក្នុងប្រទេសតង់ហ្សានី

*រូប ៦ ៖ គំរូនៃការភ្លាំងភ្លាត់ដែលលេចឡើងក្នុងឧទាហរណ៍ករណី*




---

[17] ឧទាហរណ៍ទទួលបានពីការសម្ភាសអ្នកផ្ដល់ព័ត៌មានសំខាន់ក្នុងប្រទេសនីហ្សេរីយ៉ា និងតង់ហ្សានី។

វិធីសាស្ត្រក្រុមអនាម័យ Jirani (JSG) ត្រូវបានបង្កើតឡើងក្នុងតំបន់កម្មវិធីរបស់ SNV ក្នុងប្រទេសតង់ហ្សានី ដើម្បីផ្តល់ការគាំទ្រដល់សហគមន៍នៅកម្រិតក្រុមក្នុងគោលបំណងធានាការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុង។

JSGs មានគ្រួសារ ១០ ជាសមាជិកដែលជួយគ្នាទៅវិញទៅមក ក្នុងការរក្សា និងកែលម្អការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាល ទាំងស្រុងក្នុងតំបន់ដែលខ្លួនរស់នៅ។ នៅពេលគ្រួសារមួយមានការលំបាក ដូចជាបង្គន់របស់ពួកគេដួលរលំ JSG នឹងរិះរកដំណោះស្រាយរួមគ្នា ដើម្បីឱ្យតំបន់ដែលពួកគេរស់នៅ អាចបន្តរក្សាការបញ្ឈប់ ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុងបាន។ វិធីសាស្ត្រនេះ ក៏ផ្តោតលើបញ្ហាប្រឈមរបស់គ្រួសារងាយរងគ្រោះក្នុងការធានាការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុង តាមរយៈការកំណត់រកតម្រូវការរបស់ពួកគេ និងលទ្ធភាពក្នុងការបញ្ជូនករណីទៅប្រធានក្រុម ប្រសិនបើត្រូវការជំនួយបន្ថែមទៀត។



ប្រធានក្រុម Jiraniកែសម្រួលសៀវភៅគោលបញ្ជីរបស់ខ្លួន។ អាវយឺតពណ៌ខៀវធ្វើឱ្យគេងាយសម្គាល់ក្រុមនេះហើយពួកគេទទួលបានការគោរពក្នុងសហគមន៍ប្រទេសតង់ហ្សានី។ *ក្រេឌីត ៖ SNV តង់ហ្សានី។*

វិធីសាស្ត្រនេះជាវិធីមួយ សម្រាប់ដោះស្រាយភាពខុសគ្នានៃទិន្នន័យក្នុងសៀវភៅគោលបញ្ជីអនាម័យតាមភូមិ ប៉ុន្តែត្រូវបានគេមើលឃើញថាជាយន្តការដែលមានប្រសិទ្ធភាពក្នុងការដោះស្រាយការភ្លាំងភ្លាត់ និងរក្សាការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុង តាមរយៈការគាំទ្រសហគមន៍ និងការទទួលខុសត្រូវចំពោះគ្នាទៅវិញទៅមក។ ប្រសិទ្ធភាពផ្អែកលើភាពនៅជិត (ប្រជាជនដែលត្រូវពិនិត្យអ្នក រស់នៅជិតខាងអ្នក។ ដូច្នេះ អ្នកត្រូវកែលម្អ" (Rieiro 2019)។

JSGs ជាគំនិតថ្មី ប៉ុន្តែដោយសារតែលទ្ធផលជាវិជ្ជមាន ស្រុកមួយចំនួនបានចាប់ផ្តើមពង្រីកវិធីសាស្ត្រនេះក្រៅពីតំបន់កម្មវិធីរបស់ SNV។

**ជំហាន ៖**

១. នៅពេលភូមិមួយត្រូវបានបំផុស និងប្តេជ្ញាប្រែក្លាយជាភូមិដែលបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុង ប្រធានក្រុម JSG ត្រូវបានចាត់តាំងក្នុងកិច្ចប្រជុំសហគមន៍។ ក្រុមនីមួយៗមានសមាជិក ១០ គ្រួសារ ហើយពួកគេជ្រើសរើសប្រធានក្រុមម្នាក់"[18]។

[18]គួរកត់សម្គាល់ថា ក្នុងប្រទេសតង់ហ្សានី ក្រុមអ្នកជិតខាងដែលមាន ១០ គ្រួសារ ត្រូវបានរៀបចំជាស្រេចជាក្រុម ១០ គ្រួសារដោយរដ្ឋាភិបាល។

២. ប្រធានក្រុម Jirani ឆ្លងកាត់វគ្គបណ្តុះបណ្តាលរយៈពេលមួយថ្ងៃ ដោយផ្តោតលើការប្រមូល និងរាយការណ៍ទិន្នន័យសម្រាប់សៀវភៅគោលបញ្ជីភូមិ។
៣. ប្រធានក្រុម Jirani ចុះតាមផ្ទះជាប្រចាំដើម្បីតាមដានភាពអាចរកបាន និងស្ថានភាពនៃហេដ្ឋារចនាសម្ព័ន្ធអនាម័យ។
៤. ប្រធានក្រុម Jirani ជួយឱ្យអ្នកផ្សេងទៀតកំណត់រក និងអនុវត្តវិធានការតូចៗដែលអាចធ្វើបានភ្លាមៗ ដើម្បីកែលម្អអនាម័យ និងស្តារការភ្លាំងភ្លាត់ (ដូចជាការគ្របប្រហោងចានបង្គន់ដែលចំហរចោល)។ ការភ្លាំងភ្លាត់ដែលរកឃើញនឹងត្រូវបានដោះស្រាយ និងស្តារភ្លាមៗតាមរយៈដំណោះស្រាយក្នុងមូលដ្ឋាន។
៥. ប្រធានក្រុម Jirani ទទួលបានជំនួយបច្ចេកទេសពីប្រព័ន្ធភូមិ និងបុគ្គលិកសុខភាពមូលដ្ឋានសម្រាប់ករណីភ្លាំងភ្លាត់ ដែលពិបាកដោះស្រាយ។

## គន្លឹះ និងការណែនាំស្តីពីការប្រើប្រាស់រចនាសម្ព័ន្ធគាំទ្រសហគមន៍ដើម្បីដោះស្រាយការភ្លាំងភ្លាត់[19]

- សហគមន៍ដែលជ្រើសរើសអ្នកដឹកនាំក្នុងមូលដ្ឋាន ជាជាងការចាត់តាំងអ្នកដឹកនាំដោយរដ្ឋាភិបាល នឹងបង្កើនភាពអាចទទួលយកបាន និងនិរន្តរភាពនៃវិធីសាស្ត្រនេះ។ ភាពនៅជិតសហគមន៍ (ឧ. ជាអ្នកជិតខាង មិនមែនជាបុគ្គលិកសុខភាពដែលចុះតាមផ្ទះ) ផ្តល់លទ្ធភាពភ្លាមៗ និងការគាំទ្រផ្ទាល់ ក៏ដូចជាបង្កើតការទទួលខុសត្រូវរបស់សហគមន៍ ចំពោះអ្នកជិតខាងក្នុងការស្តារការភ្លាំងភ្លាត់យ៉ាងឆាប់រហ័ស។

- ប្រទេសនីហ្សេរីយ៉ាអនុវត្តវិធីសាស្ត្រនៃការជ្រើសរើសគណៈកម្មាធិការទឹកស្អាត និងអនាម័យដោយសហគមន៍ ហើយសមាជិកត្រូវបានជ្រើសរើសនៅពេលសម្រេចបានការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុង។ នេះក៏ដោយសារតែពួកគេយល់ថា ភាពសាទររបស់សមាជិកដែលបានជ្រើសរើសក្នុងពេលបំផុស អាចសាបរលាបតាមពេលវេលា ហើយពួកគេរកបានអ្នកស្ម័គ្រចិត្តដែលអាចទុកចិត្តបានក្នុងពេលឈានទៅសម្រេចបានការបញ្ឈប់ ការបន្ទោរបង់ពាសវាលពាសកាល[20] ។

- ការផ្តល់ជំនួយជាបន្តបន្ទាប់ពីប្រភេទផ្សេងៗ ដូចជា ការផ្សព្វផ្សាយពីសារតាមដានបន្តតាមវិហារឥស្លាម វិហារគ្រិស្ត ក្រុមស្ត្រី និងគ្លីនិកពិនិត្យផ្ទៃពោះមុនពេលសម្រាល អាចទប់ស្កាត់ការភ្លាំងភ្លាត់ (Odagiri et al 2017) និងពង្រឹងការងាររបស់ក្រុមអនាម័យសហគមន៍។

---

[19]គន្លឹះទាំងនេះទទួលបានពីអ្នកផ្តល់ព័ត៌មានសំខាន់ក្នុងប្រទេសម៉ាលី នីហ្សេរីយ៉ា ហ្វីលីពីន និងតង់ហ្សានី
[20]ការសម្ភាសអ្នកផ្តល់ព័ត៌មានសំខាន់ក្នុងប្រទេសនីហ្សេរីយ៉ា

**ចាំបាច់ត្រូវមានការស្រាវជ្រាវបន្ថែម៖ ការរក្សានិរន្តរភាពក្រុមគាំទ្រក្នុងមូលដ្ឋាន និងអ្នកដែលមានទេពកោសល្យជាអ្នកដឹកនាំពីកំណើត**

ការភ្លាំងភ្លាត់កើតឡើងបន្ទាប់ពីការបញ្ចាក់ការបញ្ឈប់ ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុង។ ដូច្នេះ រចនាសម្ព័ន្ធគាំទ្រសហគមន៍ ត្រូវបន្តមានវត្តមានដើម្បីដោះស្រាយបញ្ហានេះក្នុងរយៈពេលយូរ។ មានការសន្មតថា បណ្តាញអ្នកដែលមានទេពកោសល្យជាអ្នកដឹកនាំពីកំណើត នឹងបន្តធ្វើការជាអ្នកស្ម័គ្រចិត្ត ទោះជាលែងមានការគាំទ្រពីកម្មវិធីក្តី (Wamera 2016)។ ប៉ុន្តែក្នុងករណីជាច្រើន គេរកឃើញថា ការសន្មតនេះគឺមិនពិតទេ។ ឧ. ក្នុងប្រទេសហ្សាំប៊ី អ្នកស្ម័គ្រចិត្តផ្អើមក្នុងសហគមន៍ច្រើនតែលែងគាំទ្រសកម្មភាពក្នុងសហគមន៍ ដោយសារតែលែងមានការគាំទ្រពីស្រុក ហើយអត្រាបាត់បង់របស់ WASHcoms ក្នុងប្រទេសនីហ្សេរីយ៉ាមានរហូតដល់ ៩០%*។ កម្មវិធីមួយចំនួនកំពុងរិះរកវិធីធានានិរន្តរភាពអ្នកស្ម័គ្រចិត្តសហគមន៍ ដូចជា ការបង្កើតបណ្តាញអ្នកដែលមានទេពកោសល្យជាអ្នកដឹកនាំពីកំណើតជាផ្លូវការ (ប្រទេសសេរ៉ាឡេអូន ប្រទេសសេនេហ្គាល់) ឬការផ្សារភ្ជាប់ពួកគេទៅនឹងឱកាសបង្កើតប្រាក់ចំណូល ដូចជា ស្នូនផ្ទះបាយ ការផលិតកន្សែងអនាម័យ ឬការធ្វើសាប៊ូ (ប្រទេសកេនយ៉ា ប្រទេសនីហ្សេរីយ៉ា)។ គំនិតទាំងនេះគួរឆ្លងកាត់ការវាយតម្លៃ និងគួរចងក្រងទុកជាមេរៀន សម្រាប់វិស័យនេះ (សូមមើលផងដែរ Cavill et al, 2015)។

*(*ព័ត៌មានពីការសម្ភាសអ្នកផ្តល់ព័ត៌មានសំខាន់)*

## ៣.ការគាំទ្រជាក់លាក់ដល់ក្រុមងាយរងគ្រោះដែលមានការលំបាកក្នុងការទទួលបានបង្គន់

| **កត្តាបង្កការភ្លាំងភ្លាត់ដែលបានលើកឡើង៖** | |
|---|---|
| **កត្តាបច្ចេកវិទ្យា** | • ភាពអាចប្រើប្រាស់បាន |
| **កត្តាភាពក្រីក្រ និងភាពងាយរងគ្រោះ** | |

ការស្វែងយល់ពីឌីណាមិកនៅកម្រិតគ្រួសារ និងសហគមន៍ ជួយកំណត់អត្តសញ្ញាណបុគ្គល ក្នុងគ្រួសារដែលបញ្ឈប់ ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុង ដែលមិនបាន ឬមិនអាចប្រើប្រាស់បង្គន់រចនាសម្ព័ន្ធជាប់លាប់ ដោយសារបទដ្ឋានសង្គម ឬអសមត្ថភាពរាង



កាយក្នុងការប្រើប្រាស់បង្គន់ដែលបានសង់ ក្នុងកម្មវិធីសហគមន៍ដឹកនាំអនាម័យទាំងស្រុង (House et al. 2017)។

SNV ក្នុងប្រទេសនេប៉ាល់ និង WaterAid ក្នុងប្រទេសកម្ពុជា កំពុងលើកឡើងពីតម្រូវការរបស់ជនមានពិការភាព និងការលំបាកក្នុងការប្រើប្រាស់ផ្សេងទៀត[21]។ ក្នុងប្រទេសនេប៉ាល់ ជម្រើសបង្គន់ដែលផ្តល់ភាពងាយស្រួល ត្រូវបានចងក្រងជា សៀវភៅកាត់ឡុកដើម្បីផ្តល់ជម្រើសផ្អែកតាមព័ត៌មានត្រឹមត្រូវដល់ជនពិការ (NWSSTC 2017)។ ក្នុងប្រទេសកម្ពុជាមានការប្រើប្រាស់តារាងត្រួតពិនិត្យភាពអាចប្រើប្រាស់បាន និងសុវត្ថិភាពនៃសេវា/ហេដ្ឋារចនាសម្ព័ន្ធទឹកស្អាត និងអនាម័យសម្រាប់វាយតម្លៃ និងកំណត់រកចំណុចកែលម្អ (WaterAid and DDSP 2016)។




សៀវភៅព័ត៌មានស្តីពីជម្រើសបង្គន់គ្រួសារសម្រាប់ជនពិការ និងការលំបាកនានា។ *ក្រេឌីត ៖ DWSSM/NWSSTC។*

## ករណីសិក្សា៖ ការរចនាបង្គន់ដែលងាយស្រួលប្រើប្រាស់ក្នុងប្រទេសនេប៉ាល់

*រូប ៧ ៖ គំរូនៃការភ្លាំងភ្លាត់ដែលលេចឡើងក្នុងឧទាហរណ៍ករណី*




[21]ឧទាហរណ៍ពីការសម្ភាសអ្នកផ្តល់ព័ត៌មានសំខាន់នៅប្រទេសនេប៉ាល់




ចាប់តាំងពីការអនុវត្តផែនការថ្នាក់ជាតិនៅឆ្នាំ ២០១១ ប្រទេសនេប៉ាល់សម្រេចបានវឌ្ឍនភាពជាច្រើនឆ្ពោះទៅរកការបញ្ឈប់ ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុងទូទាំងប្រទេស។ ទោះជាយ៉ាងណា ការអង្កេតថ្មីៗស្ដីពីនិរន្តរភាព (UNICEF និង GSF) បង្ហាញថា ខណៈដែលនិន្នាការជារួមមានភាពល្អប្រសើរ ការភ្លាំងភ្លាត់នៅតែកើតឡើង។ ក្នុងតំបន់កម្មវិធីរបស់ SNV ការសិក្សានិរន្តរភាពបានបង្ហាញថា បញ្ហាពាក់ព័ន្ធនឹងភាពងាយស្រួល ក្នុងការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធមានស្រាប់សម្រាប់ជនពិការនៅតែលេចឡើង ហើយការភ្លាំងភ្លាត់ត្រូវបានកត់សម្គាល់ឃើញក្នុងគ្រួសារដែលបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុង។

ការលំបាកប្រើប្រាស់រួមមាន បន្ទប់ និងទ្វារបង្គន់តូចពេក ការមិនសូវមានបង្គន់អង្គុយ និងឧបសគ្គផ្ទែករូបវន្ត ដូចជា កាំជណ្ដើរចូលទៅក្នុងបង្គន់។ ដំបូង បញ្ហាទាំងនេះត្រូវបានដោះស្រាយទៅតាមករណីនីមួយៗ ប៉ុន្តែបញ្ហាចោទគឺចាំបាច់ត្រូវបង្កើតធនធានជាក់លាក់សម្រាប់ជួយដល់បុគ្គលិកសុខភាពក្នុងការដោះស្រាយបញ្ហានេះ។

SNV បានដឹកនាំការរៀបរៀងសៀវភៅ "ជម្រើសបង្គន់គ្រួសារសម្រាប់ជនមានពិការភាព និងការលំបាក"។ សៀវភៅព័ត៌មាននេះគឺសម្រាប់ឱ្យបុគ្គលចុះមូលដ្ឋាន បុគ្គលិកសុខភាព និងអនាម័យ អ្នកស្ម័គ្រចិត្ត និងជាងសំណង់ ប្រើប្រាស់ជាមគ្គុទេសក៍លើការពិភាក្សាកម្រិតគ្រួសារ ស្ដីពីការសង់បង្គន់ដែលចំណាយតិច និងប្រើប្រាស់សម្ភារៈ ដែលរកបានក្នុងមូលដ្ឋានសម្រាប់សមាជិកគ្រួសារដែលមានការលំបាកក្នុងការប្រើប្រាស់។ សៀវភៅព័ត៌មាននេះត្រូវបានអនុម័ត និងចែកចាយតាមបណ្ដាស្រុកទាំងអស់ក្នុងប្រទេសនេប៉ាល់។


2.1.2 Walking pathway

A. Course sand pathway with stone kerb

Suitable: Visually impaired people

Features:
- Materials: course sand for pathway and small boulders for kerb
- Kerb height: less than 4 inches
- Pathway finishing: smooth, without sharp stones
- Pathway should be made as straight as possible
- Pathway needs regular maintenance to align the kerb and remove obstacles from the pathway
- Keeping light at pathway will help low vision people at night time (not illustrated)
- Pathway can also be used with a toilet having steps (not illustrated)

10

គន្លងផ្លូវដើរសម្រាប់ជនមានកម្សោយគំហើញ។
*ក្រេឌីត ៖ DWSSM/NWSSTC។*

ជំហាន៖
១. បន្ទាប់ពីការកំណត់រកការភ្លាំងភ្លាត់ពីដំបូងតាមរយៈការងារតាមមូលដ្ឋាន និងការអង្កេត ការវិភាគបញ្ហាលម្អិតត្រូវបានធ្វើឡើង។
២. មានការរិះរក និងចងក្រងដំណោះស្រាយនានាដោយប្រើឧទាហរណ៍ក្នុងមូលដ្ឋាន ឯកសារដែលបានបោះពុម្ពផ្សាយស្តីពីប្រធានបទនេះ និងការស្រាវជ្រាវតាមអ៊ីនធឺណិត។
៣. បន្ទាប់មក ដំណោះស្រាយទាំងនោះ "ត្រូវបានបញ្ជ្រាបក្នុងមូលដ្ឋាន" តាមរយៈការធ្វើការជាមួយអង្គការជនពិការ និងជាងសំណង់ក្នុងតំបន់កម្មវិធី។
៤. មានការប្រមែប្រមូលដំណោះស្រាយសមស្របនានា ដោយសហការជាមួយមជ្ឈមណ្ឌលជាតិបណ្តុះបណ្តាលការផ្គត់ផ្គង់ទឹក និងអនាម័យ។
៥. ឯកសារណែនាំត្រូវបានចែកចាយសម្រាប់ការពិនិត្យឡើងវិញយ៉ាងទូលំទូលាយក្នុងវិស័យ នេះ មុននឹងយកទៅអនុវត្ត។
៦. សម្រាប់ការអនុវត្តគំនិតផ្តួចផ្តើមក្នុងសៀវភៅព័ត៌មាននេះ SNV បានសហការជាមួយសភាពាណិជ្ជកម្ម និងឧស្សាហកម្មដើម្បីកសាងការយល់ដឹង និងពង្រឹងសង្វាក់ផ្គត់ផ្គង់ ដើម្បីធ្វើការកែសម្រួលចាំបាច់សម្រាប់ជនពិការតាមរយៈបណ្តាញតួអង្គវិស័យឯកជនរបស់ខ្លួន។

## គន្លឹះ និងការណែនាំស្តីពីការផ្តល់ការគាំទ្រជាក់លាក់ដល់ក្រុមងាយរងគ្រោះ ដើម្បីដោះស្រាយការភ្លាំងភ្លាត់[22]

- ធានាការបង្កើតវិធីសាស្ត្រដែលគ្របដណ្តប់លើក្រុមងាយរងគ្រោះបំផុតដោយសហការ និងចូលរួមដោយក្រុមពាក់ព័ន្ធទាំងអស់ ដូចជា កាកៀរគរអង្គការដែលធ្វើការក្នុងវិស័យទឹកស្អាត និងអនាម័យ រដ្ឋាភិបាលមូលដ្ឋាន និងក្រុមចំណាប់អារម្មណ៍ក្នុងមូលដ្ឋាន (ដូចជា អង្គការជនពិការ) ដើម្បីបង្កើតដំណោះស្រាយសម្រាប់ការភ្លាំងភ្លាត់ដែលសមស្រប និងផ្អែកតាមបរិបទ។

- បង្កើតប្រព័ន្ធពិនិត្យតាមដានក្នុងមូលដ្ឋាន ដែលខិតខំកំណត់អត្តសញ្ញាណក្រុមដែលងាយរងគ្រោះបំផុតក្នុងបរិបទណាមួយ និងប្រឈមនឹងហានិភ័យខ្លាំងបំផុតដោយសារការភ្លាំងភ្លាត់។ឧ.កម្មវិធីKSHIPក្នុងប្រទេសកេនយ៉ាបានកំណត់អត្តសញ្ញាណគ្រួសារងាយរងគ្រោះក្នុងពេលគូសផែនទីសហគមន៍ រួចតាមដានបន្តលើពួកគេតាមបែបប្រតិសកម្ម (IDS 2018)។

- កសាងសមត្ថភាពរបស់បុគ្គលិកសុខភាព និងអ្នកដែលមានទេពកោសល្យជាអ្នកដឹកនាំពីកំណើតក្នុងការកត់សម្គាល់ឧបសគ្គដែលអាចរារាំង ការប្រើប្រាស់និងបង្កជាការភ្លាំងភ្លាត់។ ចំណុចនេះរួមមានការត្រួតពិនិត្យភាពអាចប្រើប្រាស់បាន ឬឧបករណ៍ផ្សេងទៀតដើម្បីកំណត់រកការភ្លាំងភ្លាត់ និងយុទ្ធសាស្ត្រស្តារការភ្លាំងភ្លាត់ (សូមមើលផងដែរឯកសារទី ៣ ក្នុងកម្រងឯកសារនេះ)។

[22]គន្លឹះទទួលបានពីអ្នកផ្តល់ព័ត៌មានសំខាន់ក្នុងប្រទេសនេប៉ាល់ និងឯកសារមានស្រាប់

## ៩.ការដោះស្រាយការភ្លាំងភ្លាត់ដែលបង្កឡើងដោយឥរិយាបថបោះចោលលាមកកុមារ

| កត្តាបង្កការភ្លាំងភ្លាត់ដែលបានលើកឡើង៖ | |
|---|---|
| **កត្តាបច្ចេកវិទ្យា** | • ជំនឿពាក់ព័ន្ធនឹងលាមកកុមារ |

មានការលើកឡើងជាញឹកញាប់ថា ការបោះចោលលាមកកុមារមិនបានត្រឹមត្រូវជាបុព្វហេតុបង្កជាការបន្ទោរបង់ពាសវាលពាសកាល សូម្បីតែក្នុសហគមន៍ដែលបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុង ព្រោះកុមារតូចៗមិនប្រើបង្គន់[23] ឬម្តាយ និងអ្នកថែទាំបោះចោលលាមកទារកដោយគ្មានអនាម័យ[24] [25]។ ចាំបាច់ត្រូវមានសកម្មភាពផ្លាស់ប្តូរឥរិយាបថតាមរយៈការប្រាស្រ័យទាក់ទង ដែលច្បាស់លាស់ និងផ្អែកតាមភស្តុតាងដើម្បីផ្លាស់ប្តូរការយល់ឃើញ និងការអនុវត្ត។ ទោះជាយ៉ាងណា មានឧទាហរណ៍តិចតួចនៃយុទ្ធសាស្ត្រ ឬវិធីសាស្ត្រជាក់លាក់ដើម្បីដោះស្រាយការបោះបោលលាមកកុមារមិនបានត្រឹមត្រូវ[26] ។ ក្នុងករណីជាច្រើន ប្រហែលជាគ្មានការដាក់បញ្ចូលលាមកកុមារជាលក្ខណៈវិនិច្ឆ័យក្នុងការបញ្ជាក់ ការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុងទេ ប៉ុន្តែក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ ចំណុចនេះត្រូវបានចាត់ទុកជាធាតុផ្សំដ៏សំខាន់ក្នុងការសម្រេចបានបរិស្ថានស្អាត ដែលគ្មានការបន្ទោរបង់ពាសវាលពាសកាល។ ដូច្នេះការភ្លាំងភ្លាត់សំដៅលើការមិនសម្រេចបានលក្ខណៈវិនិច្ឆ័យបន្ថែម។

**ករណីសិក្សា ៖ ការធ្វើការជាមួយផ្នែកអាហារូបត្ថម្ភដើម្បីដោះស្រាយការភ្លាំងភ្លាត់ទៅរកការបន្ទោរបង់ពាសវាលពាសកាល ៖ ការរៀនសូត្រថ្មីៗពីប្រទេសហ្វីលីពីន**

*រូប ៨ ៖ គំរូនៃការភ្លាំងភ្លាត់ដែលលេចឡើងក្នុងឧទាហរណ៍ករណី*




[23]ការសម្ភាសអ្នកផ្តល់ព័ត៌មានសំខាន់ក្នុងប្រទេសនីហ្សេរីយ៉ា និងម៉ាលី
[24]ការសម្ភាសអ្នកផ្តល់ព័ត៌មានសំខាន់ក្នុងប្រទេសហ្វីលីពីន
[25] ករណីញឹកញាប់គឺលាមកកុមារមិនត្រូវបានដាក់បញ្ចូលក្នុងលក្ខណៈវិនិច្ឆ័យនៃការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុង ឬក៏គ្មានការធានាស្ថិរភាពបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុងដែលពាក់ព័ន្ធនឹងលាមកកុមារក្នុងអំឡុងពេលផ្ទៀងផ្ទាត់។
[26]ការសម្ភាសអ្នកផ្តល់ព័ត៌មានសំខាន់ក្នុងប្រទេសហ្វីលីពីន




ក្នុងប្រទេសហ្វីលីពីន ខណៈដែលសហគមន៍នានាខិតខំប្រែក្លាយជាសហគមន៍ដែលបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុង ការបោះចោលលាមក និងខោទឹកនោមរបស់កុមារដោយគ្មានអនាម័យនៅកន្លែងចាក់សំរាម ឬកណ្តាលវាល នៅតែកើតមាន ឬភ្លាំងភ្លាត់បន្ទាប់ពីការបញ្ជាក់ការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុង។

ជាការឆ្លើយតប UNICEF និងដៃគូរដ្ឋាភិបាលមកពីនាយកដ្ឋានអនាម័យនិងនាយកដ្ឋានអាហារូបត្ថម្ភ បានសាកល្បងវិធីសាស្ត្រសហាការអន្តរវិស័យដែលបង្កប់សារនៃការបញ្ឈប់ ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុងពាក់ព័ន្ធនឹងការបោះចោលខោទឹកនោម និងលាមកកុមារបានត្រឹមត្រូវ ក្នុងយុទ្ធសាស្ត្រផ្សព្វផ្សាយរបស់កម្មវិធី ១០០០ ថ្ងៃដំបូងនៃវិស័យអាហារូបត្ថម្ភ។ វិធីសាស្ត្រនេះនឹងត្រូវបានអនុវត្តដោយបណ្តាញបញ្ញវន្តអាហារូបត្ថម្ភសហគមន៍មានស្រាប់នៅកម្រិតសហគមន៍[27]។ ពួកគេត្រូវបានដាក់ពង្រាយដើម្បីពង្រឹងសារនៃការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុង និងផ្តោតជាពិសេសលើកុមារ និងអ្នកថែទាំកុមារ។

ការបង្កើតយុទ្ធសាស្ត្រ ពិធីសារ និងឧបករណ៍ផ្លាស់ប្តូរឥរិយាបថ ផ្អែកតាមការស្រាវជ្រាវបណ្តើរៗដែលបានធ្វើឡើងក្នុងទីក្រុង Quezon និងខេត្តសាម៉ាខាងជើង និងត្រូវអនុវត្តសាកល្បងនៅអំឡុងឆ្នាំ ២០១៩-២០២០។

**ជំហាន ៖**

១. មានការទទួលយកនិរន្តរភាព នៃការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុងកាន់តែច្រើន នៅពេលដែលកម្មវិធីនេះផ្តោតលើការសម្រេចបានលទ្ធផលកង្វះអាហារូបត្ថម្ភក្នុង "រយៈពេល ១០០០ ថ្ងៃដំបូង" ។ កម្មវិធីនេះបានងាកមកផ្តោតការយកចិត្តទុកដាក់លើកុមារក្រិះក្រិន ដែលរងផលប៉ះពាល់អវិជ្ជមានដោយសារការបន្ទោរបង់ពាសវាលពាសកាល។

[27] មានបញ្ញវន្តអាហារូបត្ថម្ភម្នាក់ក្នុងសហគមន៍មួយ។ ពួកគេជាអ្នកស្ម័គ្រចិត្ត និងបម្រើឱ្យផលប្រយោជន៍សហគមន៍របស់ខ្លួន។

២. ការស្រាវជ្រាវបណ្តើរៗ មានគោលបំណងកំណត់រកបញ្ហាសំខាន់ៗដែលត្រូវដោះស្រាយសម្រាប់កុមារក្នុងរយៈពេល ១០០០ ថ្ងៃដំបូង និងកត្តាដែលអាចជំរុញការផ្លាស់ប្តូរឥរិយាបថ។
៣. យុទ្ធសាស្ត្រផ្លាស់ប្តូរឥរិយាបថតាមរយៈការប្រាស្រ័យទាក់ទង ត្រូវបានបង្កើតឡើងក្រោមកិច្ចសហការរបស់ក្រុមទំនាក់ទំនងដើម្បីការអភិវឌ្ឍ នឹងទូទាំងវិស័យ។
៤. យុទ្ធនាការ ដែលរួមបញ្ចូលឧបករណ៍/សម្ភារៈផ្លាស់ប្តូរឥរិយាបថ និងសង្គមនឹងត្រូវបានបង្កើតឡើង នឹងសាកល្បងជាមុន។
៥. វិធីសាស្ត្រនេះនឹងត្រូវបានអនុវត្តសាកល្បងនៅថ្នាក់ខេត្ត និងក្រុង តាមរយៈប្រព័ន្ធរដ្ឋាភិបាលមានស្រាប់ (ឧ. អធិការអនាម័យជនបទ បុគ្គលិកសុខភាព Barangay បញ្ញវន្តអាហារូបត្ថម្ភ Barangay និងប្រធានត្រួតពិនិត្យរបស់ពួកគេ)។

### គន្លឹះ និងការណែនាំសម្រាប់ការដោះស្រាយការត្លាំងត្លាត់ដែលពាក់ព័ន្ធនឹងការបោះចោលលាមកកុមារ និងទារក

- រិះរកឱកាសជំរុញការចូលរួមរបស់កុមារ និងអ្នកថែទាំតាមរយៈបណ្តាញអន្តរវិស័យ។ កម្មវិធីចាក់ថ្នាំបង្ការ និងការពិគ្រោះយោបល់ស្តីពីអាហារូបត្ថម្ភនឹងកំណត់យកកុមារ និងអ្នកថែទាំកុមារជាចំណុចផ្តោតនៃអន្តរាគមន៍របស់ខ្លួន ហើយពួកគេនឹងក្លាយជាក្រុមអាទិភាពសម្រាប់ការកំណត់រក និងដោះស្រាយការត្លាំងត្លាត់។
- ប្រើប្រាស់ការស្រាវជ្រាវបណ្តើរៗ និងមតិយោបល់ពីវិស័យផ្សេងទៀតដែលផ្តោតលើឪពុកម្តាយថ្មី និងអ្នកថែទាំកុមារ ដើម្បីបង្កើតគំនិតផ្តួចផ្តើមផ្លាស់ប្តូរឥរិយាបថដែលថ្មីស្រឡាង មានភាពពាក់ព័ន្ធ និងសមស្របក្នុងការដោះស្រាយកត្តាបង្កការត្លាំងត្លាត់ជាក់លាក់។
- ការបង្រៀនឱ្យកុមារចេះប្រើបង្គន់ ជាកត្តាដ៏សំខាន់មួយក្នុងការបំពាក់បំប៉នការបញ្ឈប់ ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុងជាបទដ្ឋានសង្គម ក្នុងសហគមន៍។ ដោយសារតែលាមកកុមារជាកត្តាដ៏សំខាន់ដែលបង្កជាការត្លាំងត្លាត់ក្នុងបរិបទជាច្រើន ចាំបាច់ត្រូវបង្កើតនិងចែករំលែកយុទ្ធសាស្ត្រជាក់លាក់ដើម្បីចូលដល់កុមារ និងអ្នកថែទាំ និងលើកកម្ពស់ការផ្លាស់ប្តូរឥរិយាបថ។

## ៥.ការកសាងភាពធន់នឹងវិបត្តិខាងក្រៅ

| កត្តាបង្កការត្លាំងត្លាត់ដែលបានលើកឡើង៖ | |
|---|---|
| **កត្តាខាងក្រៅ** | • អ្នកចំណូលស្រុក/ភៀស |

បំលាស់ទីប្រជាជនទៅក្នុងតំបន់ដែលបញ្ឈប់ ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុង អាចបង្កជាការភ្លាំងភ្លាត់ ប្រសិនបើអ្នកចំណូលស្រុកមិនអនុវត្តតាមលក្ខណៈវិនិច្ឆ័យនៃការបញ្ឈប់ ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុង។ បំលាស់ទីទាំងនេះអាចមានទ្រង់ទ្រាយតូច ឬធំ អាចព្យាករបាន ឬភ្លាមៗ បណ្តោះអាសន្ន ឬយូរអង្វែង។ ឧទាហរណ៍ខាងក្រោមដកស្រង់ចេញពីប្រទេសនីហ្សេរីយ៉ា ដែលមានលំហូរចូលភ្លាមៗនៃជនភៀសខ្លួន។ ចំណុចនេះបានបង្កជាការភ្លាំងភ្លាត់នៃការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុង និងជាបញ្ហាដែលត្រូវដោះស្រាយបន្ទាន់។

**ករណីសិក្សា ៖ ការបង្កើនសិទ្ធិអំណាចរបស់ WASHcoms ក្នុងប្រទេសនីហ្សេរីយ៉ាដើម្បីប្រយុទ្ធប្រឆាំងការបន្ទោរបង់ពាសវាលពាសកាលដែលអាចកើតឡើង**

*រូប ៩ ៖ គំរូនៃការភ្លាំងភ្លាត់ដែលលេចឡើងក្នុងឧទាហរណ៍ករណី*




សហគមន៍ដែលបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលក្នុងតំបន់កម្មវិធី United Purpose អាចស្តារការភ្លាំងភ្លាត់ដែលបង្កឡើងដោយលំហូរចូលនៃជនភៀសខ្លួនបានយ៉ាងឆាប់រហ័ស និងធានាបានស្ថានភាពនៃការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុង ទោះបីជាមានសម្ពាធបន្ថែមទៀតលើប្រព័ន្ធមានស្រាប់ក្តី។

នៅខែ កញ្ញា ឆ្នាំ ២០១៨ ជនភៀសខ្លួនចំនួន ៦០០០-៨០០០ នាក់មកពីប្រទេសកាមេរូន បានឆ្លងដែនចូលទៅក្នុងប្រទេសនីហ្សេរីយ៉ាភាគអាគ្នេយ៍ ដើម្បីស្វែងរកសិទ្ធិជ្រកកោនក្នុងប្រទេសអ៊ុយហ្គង់ដា (តំបន់រដ្ឋាភិបាលមូលដ្ឋាន Obanliku ក្នុងរដ្ឋ Cross River)។ ប្រទេសនីហ្សេរីយ៉ា ធ្លាប់ជាតំបន់ដែលត្រូវបានផ្ទៀងផ្ទាត់ការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុង។ ជនភៀសខ្លួនទាំងនេះត្រូវបានដាក់ឱ្យស្នាក់នៅជាមួយគ្រួសារនានាក្នុងសហគមន៍ ឬស្នាក់នៅក្នុងជម្រកបណ្តោះអាសន្នក្នុងភូមិ។ អ្នកចំណូលស្រុកយ៉ាងច្រើនដែលគ្មានបង្គន់ប្រើប្រាស់ បានចាប់ផ្តើមបង្កការរំខានដល់ស្ថានភាពបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុង របស់សហគមន៍។ ដោយយកត់សម្គាល់ពីការភ្លាំងភ្លាត់ និងមិនចង់បាត់បង់ស្ថានភាពបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុងរបស់ខ្លួន WASHcoms បានរៀបចំកិច្ចប្រជុំភ្លាមៗជាមួយជនភៀសខ្លួន ដើម្បីពន្យល់ពីវិធាននៃការបញ្ឈប់ ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុងក្នុងតំបន់នោះ។ WASHcoms បានរៀបចំការអនុញ្ញាតឱ្យជនភៀសខ្លួនប្រើប្រាស់បង្គន់ក្នុងសហគមន៍ ដើម្បីកុំឱ្យពួកគេមានលេសបន្ទោរបង់ក្នុងគុម្ពោតព្រៃ។

ក្នុងរយៈពេលខ្លី សហគមន៍ចង់ប្រើបង្គន់រួមជាមួយអ្នកចំណូលស្រុក ជាជាងវិលទៅរកស្ថានភាពបន្ទោរបង់ពាសវាលពាសកាល។ ឯកសារមានស្រាប់បង្ហាញថា ការប្រើបង្គន់រួមអាចបង្កជាការភ្លាំងភ្លាត់ (Pasteur 2012)។ ដូច្នេះ ខណៈដែលការរៀបចំនេះហាក់គ្មានប្រសិទ្ធភាពក្នុងរយៈពេលវែង ចំណុចនេះបង្ហាញថា មានបទដ្ឋានសង្គមដ៏រឹងមាំជាស្រេចហើយ WASHcoms យល់ថាទទួលបានសិទ្ធិអំណាច ក្នុងការទទួលខុសត្រូវលើស្ថានភាពបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុងរបស់សហគមន៍ ជាជាងរង់ចាំជំនួយពីខាងក្រៅ។

## គន្លឹះ និងការណែនាំសម្រាប់ការដោះស្រាយការភ្លាំងភ្លាត់ដែលបង្កឡើងដោយអ្នកចំណូលស្រុក

- មានការធ្វើចំណាត់ការភ្លាមលើការភ្លាំងភ្លាត់ក្នុងប្រទេសនីហ្សេរីយ៉ា ដោយសារតែ WASHcoms យល់ថាមានសិទ្ធិអំណាចក្នុងការចាត់វិធានការជំនួសមុខឱ្យសហគមន៍ ជាជាងរង់ចាំឱ្យទីភ្នាក់ងារខាងក្រៅ "ប្រឈមមុខជាមួយ" ជនភៀសខ្លួន។ ទោះបីជា WASHcoms ជាអ្នកស្ម័គ្រចិត្តក្តី ប៉ុន្តែពួកគេមានស្មារតីទទួលបានសិទ្ធិអំណាចតាមរយៈការបណ្តុះបណ្តាលមូលដ្ឋាន និងការអញ្ជើញឱ្យពួកគេចូលរួមប្រជុំជាមួយបុគ្គលិកសុខភាពដែលទទួលបានប្រាក់ឈ្នួល និងមន្ត្រីមូលដ្ឋានដែលបង្ហាញការគោរព និងសារៈសំខាន់របស់ពួកគេក្នុងសហគមន៍។
- បទដ្ឋានសង្គមដ៏រឹងមាំ និងលក្ខន្តិកៈក្នុងមូលដ្ឋាន ដែលត្រូវបានបង្កើតឡើងប្រឆាំងនឹងការបន្ទោរបង់ពាសវាលពាសកាល ជាលក្ខខណ្ឌតម្រូវឱ្យអ្នកចំណូលស្រុកខិតខំធ្វើយ៉ាងណាមិនឱ្យភ្លាំងភ្លាត់ស្ថានភាពបញ្ឈប់ ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុង។ តាមពិត មិនថាអ្នកចំណូលស្រុកត្រូវបានស្នើឱ្យ

សង់បង្គន់ ឬអត់នោះទេ វាជាវិធានការមួយ ដែលបង្ហាញពីកម្រិតនៃការផ្លាស់ប្តូរបទដ្ឋានសង្គម[28] ។ ផ្លាកសញ្ញាដែលបង្ហាញពី តំបន់បញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុងក្នុងប្រទេសកេនយ៉ាង និងប្រទេស ផ្សេងទៀត និងការប្រើប្រាស់ ទង់ជាតិ ដើម្បីបង្ហាញពីស្ថានភាពបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុងក្នុងប្រទេសអេត្យូពី សុទ្ធតែជាវិធីដែលមានប្រសិទ្ធភាពក្នុងការបង្ហាញពីការមិនទទួលយកអ្នកចំណូលស្រុកដែលបន្ទោរបង់ពាសវាលពាសកាល។



ក្តារប្រកាសព័ត៌មានក្នុងប្រទេសអេត្យូពី។ *ក្រេឌីត ៖ Jamie Myers*

- សម្រាប់បំលាស់ទីប្រជាជនដែលអាចព្យាករណ៍បាន ដូចជាភ្ញៀវឈប់សម្រាកតាមមហាវិថី ឬក្រុមគង្វាលសត្វ បង្គន់សាធារណៈអាចជាដំណោះស្រាយដែលមានប្រសិទ្ធភាពសម្រាប់ការភ្លាំងភ្លាត់ដែលបង្កឡើងដោយអ្នកចំណូលស្រុក។

## ៦.ផែនការសកម្មភាពក្រោយការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុង

ផ្អែកតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ចាំបាច់ត្រូវមានការផ្លាស់ប្តូរពីការផ្តោតសំខាន់លើសហគមន៍ ដែលបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុងទៅរកការចាត់ទុកការប្រកាសការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុង ជាវិធីរក្សានិរន្តរភាពឥរិយាបថអនាម័យ ដែលគាំទ្រដោយសេវាដែលគ្រប់គ្រងដោយសុវត្ថិភាព។ មានការទទួលស្គាល់ថា ការវិវឌ្ឍឆ្ពោះឡើងលើនៃកាំជណ្តើរអនាម័យ មិនកើតឡើងដោយឯកឯងនោះទេ (UNICEF 2016) ហើយនៅពេលគ្មានការគ្រោងជំហានបន្ទាប់គេប្រហែលជាមិនអាចធានាថា សកម្មភាពក្រោយការបំផុសនឹងផ្តល់ផលវិជ្ជមានបានឡើយ (Jacob 2018)។

ប្រទេសជាច្រើន ចាប់ផ្តើមបង្កើតយុទ្ធសាស្ត្រក្រោយការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុងដែលជំរុញវឌ្ឍនភាពអនាម័យ តាមរយៈការអនុវត្តដំណាក់កាលជាមុន។ សកម្មភាពក្រោយការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុង (ឬ ODF+, អនាម័យទាំងស្រុង។ល។) ជួយបង្កើននិរន្តរភាពនៃការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុង តាមរយៈការពង្រឹងឥរិយាបថ និងការលើកទឹកចិត្តឱ្យឈានឡើងកាំជណ្តើរអនាម័យ ឆ្ពោះទៅរកហេដ្ឋារចនាសម្ព័ន្ធដែលជាប់ធន់ និងសេវាអនាម័យបរិស្ថានកម្រិតខ្ពស់ ដូចជា ការគ្រប់គ្រងភក់លាមក (Bevan and Thomas 2013; Gib

[28]ការសម្ភាសអ្នកផ្តល់ព័ត៌មានសំខាន់ក្នុងប្រទេសអេត្យូពី

son etal 2018; Robinson and Gnilo 2016)។ ក្នុងសង្វាក់នេះ នៅពេលដែលនិន្នាការជារួមមានទិសដៅវិជ្ជមាន ការភ្លាំងភ្លាត់ដែលអាចកើតឡើងនឹងត្រូវបានស្តារ។

យុទ្ធសាស្ត្រក្រោយការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុង មានសមាសភាគដែលពង្រឹងឱ្យគ្នាទៅវិញទៅមកដូចខាងក្រោម៖

- **ផែនការ៖** ផែនការកម្រិតសហគមន៍ និងស្រុកដែលចែងពីរបៀបធានានិរន្តរភាព និងកែលម្អការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុង ដើម្បីសម្រេចបានកម្រិតបញ្ជាក់បន្ទាប់។
- **ប្រព័ន្ធ និងឧបករណ៍ពិនិត្យតាមដាន៖** ដែលអាចតាមដានវឌ្ឍនភាព និងកំណត់រកការភ្លាំងភ្លាត់។ ឧ. SNV ក្នុងប្រទេសនេប៉ាល់ បានបង្កើតឧបករណ៍កំណត់រកពីដំបូងដើម្បីកំណត់រកការភ្លាំងភ្លាត់ដែលអាចកើតឡើង (Regmi 2016)។
- **ការចុះតាមដានបន្ត៖** សម្រាប់ផ្តល់ការគាំទ្រ និងការលើកទឹកចិត្តបន្ត។
- **សកម្មភាពផ្លាស់ប្តូរឥរិយាបថ តាមរយៈការប្រាស្រ័យទាក់ទងដោយផ្តែកលើភស្តុតាង សម្រាប់ការពង្រឹងឥរិយាបថ៖** ច្រើនតែផ្តែកលើលក្ខខណ្ឌដំបូងនៃការបញ្ឈប់ ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុង ដើម្បីដាក់បញ្ចូលឥរិយាបថអនាម័យបន្ថែម។
- **ការផ្សព្វផ្សាយពីបច្ចេកវិទ្យាដែលកាន់តែជាប់ធន់៖** ឧ. តាមរយៈការបណ្តុះបណ្តាលជាងសំណង់ ឬការផ្សារភ្ជាប់ទៅនឹងទីផ្សារអនាម័យ និងជំនួយខាងក្រៅ។

**ករណីសិក្សា ៖ វិធានការក្រោយការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុងក្នុងប្រទេសម៉ាលី ៖ ទស្សនៈវិស័យរយៈពេលវែងសម្រាប់និរន្តរភាពនៃការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុង[29]**

បន្ទាប់ពីបានអនុវត្តកម្មវិធីសហគមន៍ដឹកនាំអនាម័យទាំងស្រុងជាច្រើនឆ្នាំ វិស័យអនាម័យរបស់ប្រទេសម៉ាលី បានប្រឈមនឹងឧបសគ្គក្នុងការធានាការផ្លាស់ប្តូរឥរិយាបថ និងភាពជាប់ធន់នៃបង្គន់ដែលបានសង់ក្នុងសហគមន៍ដែលបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុង។ ការអនុវត្តយុទ្ធសាស្ត្រក្រោយការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុងនៅឆ្នាំ ២០១៤ ខិតខំធ្វើយ៉ាងណាឱ្យសហគមន៍កំណត់រកចំណុចខ្វះខាតដោយខ្លួនឯង រៀបចំផែនការលុបបំបាត់ចំណុចខ្វះខាតដោយអនុវត្តសកម្មភាពសមស្របតាមបរបទ និងបង្កើតមូលដ្ឋានសម្រាប់ធានានិរន្តរភាព។

[29]ការសម្ភាសអ្នកផ្តល់ព័ត៌មានសំខាន់ និង UNICEF 2017

ដំណាក់កាលក្រោយការបញ្ឈប់ ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុង ខិតខំពង្រឹង និងរក្សាបានការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុង កន្លងមក ក៏ដូចជាកែលម្អបង្គន់ ធានាអនាម័យ និងផ្ទេរការទទួលខុសត្រូវ និងភាពម្ចាស់ការទៅសហគមន៍។ លក្ខណៈវិនិច្ឆ័យក្រោយការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុងរួមបញ្ចូលសូចនាករ ៧ ជាអាទិ៍ ការមានបង្គន់ និងឥរិយាបថ និងភាពម្ចាស់ការរបស់គណៈកម្មាធិការទឹកស្អាត និងអនាម័យក្នុងមូលដ្ឋានលើដំណើរការនេះ។

ផែនការសកម្មភាពក្រោយការបញ្ឈប់ ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុងនៅថ្នាក់ភូមិ ត្រូវបានបង្កើតឡើងដោយគណៈកម្មាធិការទឹកស្អាត និងអនាម័យភូមិ និងដាក់បញ្ចូលក្នុងផែនការអភិវឌ្ឍន៍ឃុំ[30]។ ឃុំ ទទួលខុសត្រូវលើលទ្ធភាពប្រើប្រាស់ទឹក នឹងអនាម័យក្នុងតំបន់របស់ខ្លួន និងមានមេឃុំរងជាអ្នកទទួលខុសត្រូវលើទឹកស្អាត និងអនាម័យ។

កតិកាសញ្ញានិរន្តរភាពត្រីភាគី ដែលចុះហត្ថលេខាដោយភូមិ សេវាបច្ចេកទេស និងមេឃុំ ដែលកំណត់ពីការទទួលខុសត្រូវ បានផ្តល់គណនេយ្យភាព និងអាទិភាពផ្នែកគោលនយោបាយលើផ្នែកអនាម័យ។

ក្នុងរយៈពេលពីរឆ្នាំចុងក្រោយ ភូមិចំនួន ១៣០ (១០ ឃុំ) បានបង្កើតកតិកាសញ្ញា និងប្តេជ្ញាដាក់បញ្ចូលសកម្មភាពក្រោយការបញ្ឈប់ ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុងក្នុងផែនការអភិវឌ្ឍន៍ឃុំ។ ភូមិជាង ១០០០ បានបញ្ចប់ដំណាក់កាលក្រោយការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុងតាំងពីឆ្នាំ២០១៥។

**ជំហាន ៖**

១. គណៈកម្មាធិការទឹកស្អាត និងអនាម័យភូមិ ត្រូវបានជ្រើសរើសក្នុងដំណាក់កាលបំផុស និងចូលរួមដោយសមាជិកដែលបានជ្រើសរើសដើម្បីតំណាងឱ្យតំបន់ដែលពួកគេរស់នៅ និងវិស័យផ្សេងៗក្នុងសហគមន៍ (ឧ.យុវជន ស្ត្រី)។ គណៈកម្មាធិការនេះឆ្លងកាត់ការបណ្តុះបណ្តាលស្តីពីតួនាទីរបស់ខ្លួន ដូចជាការផ្តល់ការណែនាំបច្ចេកទេស ការធ្វើផែនការ និងការតាមដានបន្ត និងការកៀរគរមូលនិធិ។

២. ក្រោយការបញ្ជាក់ការបញ្ឈប់កា របន្ទោរបង់ពាសវាលពាសកាលទាំងស្រផែនការសកម្មភាពក្រោយការបញ្ឈប់ ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុងត្រូវបានបង្កើតឡើងដោយគណៈកម្មាធិការទឹកស្អាត និងអនាម័យ។

៣. ការផ្តល់សុពលភាពជាលើកដំបូង ត្រូវបានធ្វើឡើងដោយសេវាបច្ចេកទេសរដ្ឋាភិបាល និងទីភ្នាក់ងារគាំទ្រដើម្បីធានាថា គណៈកម្មាធិការនេះបំពេញមុខ

[30]ឃុំជាសហគមន៍ដែលមានភូមិ ១០-៤០ ក្រោមការដឹកនាំរបស់មេឃុំដែលបានជ្រើសតាំង។

ងារ និងមានការអនុវត្តផែនការសកម្មភាព។

៤. គណៈកម្មាធិការនេះអនុវត្ត និងធានាការអនុលោមតាមផែនការសកម្មភាព។ ពួកគេចុះតាមផ្ទះ និងផ្តល់ការណែនាំពីរបៀបងាកមកគន្លងត្រឹមត្រូវវិញប្រសិនបើមានការភ្លាំងភ្លាត់។

៥. បុគ្គលិករដ្ឋាភិបាលបានចុះត្រួតពិនិត្យ ចំណែកទីភ្នាក់ងារគាំទ្របានអនុវត្តកម្មភាពនានា ដូចជា ការផ្លាស់ប្តូរឥរិយាបថតាមរយៈការប្រាស្រ័យទាក់ទង ការបណ្តុះបណ្តាលជាងសំណង់ និងការបណ្តុះបណ្តាលបន្ថែមទៀតដល់គណៈកម្មាធិការទឹកស្អាត និងអនាម័យ។

៦. ការវាយការណ៍ដោយសហគមន៍ផ្ទាល់នៅតែធ្វើឡើង រហូតទាល់តែពួកគេយល់ថាបានបញ្ចប់ផែនសកម្មភាពក្រោយការបញ្ឈប់ ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុង។

៧. ការផ្ទៀងផ្ទាត់លើកទីពីរចូលរួមដោយសហគមន៍ សេវាបច្ចេកទេស និងទីភ្នាក់ងារគាំទ្រពីខាងក្រៅ។មានការអង្កេតKAPនិងការផ្ទៀងផ្ទាត់លក្ខណៈវិនិច្ឆ័យទាំងអស់។ បន្ទាប់ពីការផ្ទៀងផ្ទាត់លើកទី ២ នឹងមានការចេញសេចក្តីសម្រេចថា តើត្រូវបញ្ជាក់ស្ថានភាពក្រោយគ្មានការបន្ទោរបង់ពាសវាលពាសកាល ទាំងស្រុងឬយ៉ាងណា។

៨. វដ្តនៃការរៀបចំផែនការ និងការវាយតម្លៃក្រោយការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុង ធ្វើឡើងជារៀងរាល់ឆ្នាំ និងចូលរួមដោយត្រីភាគី។

## គន្លឹះ និងការណែនាំសម្រាប់ការអនុវត្តបន្តក្រោយការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុង

- ការជំរុញអនាម័យ តាមរយៈការរៀបចំកម្មវិធីក្រោយការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុង ទាមទារការចូលរួម និងការរៀបចំផែនការរយៈពេលវែង។ ការធ្វើឱ្យវិធីសាស្ត្រនេះក្លាយជាយុទ្ធសាស្ត្រថ្នាក់ជាតិ និងការតម្រូវឱ្យអ្នកអនុវត្តន៍ទាំងអស់ ចាប់ផ្តើមកម្មវិធីសហគមន៍ដឹកនាំអនាម័យទាំងស្រុងក្នុងសហគមន៍ថ្មីៗ ដើម្បីដាក់បញ្ចូលសកម្មភាពបញ្ជាក់ក្រោយការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុង ក្នុងការធ្វើផែនការរបស់ខ្លួន ដូចការអនុវត្តក្នុងប្រទេសម៉ាលី ជាគន្លឹះក្នុងការធានាការផ្លាស់ប្តូរពីការផ្តោតសំខាន់លើការសម្រេចបានការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុងទៅជាការសម្រេចបានគោលដៅអនាម័យប្រកបដោយមហិច្ឆិតាជាងមុន។

- សកម្មភាព ក្រោយការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាល ទាំងស្រុងទាមទារទាំងធនធានមនុស្ស និងហិរញ្ញវត្ថុដែលត្រូវគ្រោងឡើងពីដំបូងដើម្បីធានាថា ប្រព័ន្ធរដ្ឋាភិបាលមូលដ្ឋាន មានសមត្ថភាពចាំបាច់ក្នុងការអនុវត្ត (Wamera 2016; USAID 2017)។

- ការជំរុញការចូលរួមរបស់ថ្នាក់ដឹកនាំ និងស្ថាប័នកម្រិតខ្ពស់ដែលចាប់អារម្មណ៍លើសកម្មភាពទាំងនេះ (ឧ. មេឃុំនៅប្រទេសម៉ាលីចុះពិនិត្យសហគមន៍រាល់ឆ្នាំ) នឹងផ្តល់ការគាំទ្រ និងការលើកទឹកចិត្តឱ្យមានការធានានិរន្តរភាពការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុង។ ជាញឹកញាប់ សេវាកម្រិតខ្ពស់ក្នុងសកម្មភាព ក្រោយការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុង បានទាក់ទាញចំណាប់អារម្មណ៍របស់អ្នកនយោបាយ (Robinson and Gnilo 2016)។

- ការបង្កើតប្រព័ន្ធតាមដាន និងរាយការណ៍ក្នុងមូលដ្ឋាន (ឧ. បណ្តាញត្រួតពិនិត្យសហគមន៍តាមសាលារៀនក្នុងប្រទេសអេត្យូពី ឬឧបករណ៍កំណត់រកការភ្លាំងភ្លាត់ពីដំបូងក្នុងប្រទេសនេប៉ាល់) ជួយឱ្យសកម្មភាពក្រោយការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុង ផ្តោតលើការភ្លាំងភ្លាត់ដែលបានកត់សម្គាល់។

## ការដោះស្រាយការភ្លាំងភ្លាត់ ៖ គំនិតពីមូលដ្ឋាន

ឧទាហរណ៍គំរូទាំងនេះលើកឡើងពីគំរូ និងកត្តាផ្សេងៗដែលបង្កការភ្លាំងភ្លាត់ និងបានផ្តល់មេរៀនសំខាន់ៗមួយចំនួនសម្រាប់ការអនុវត្តក្នុងបរិបទនានា។

១. **ត្រៀមខ្លួនសម្រាប់ការភ្លាំងភ្លាត់ ៖** សូមយល់ថា ការភ្លាំងភ្លាំងនៃការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុង ងាយនឹងកើតឡើងក្នុងកម្មវិធីសហគមន៍ដឹកនាំអនាម័យអនុវត្តទាំងស្រុងភាគច្រើន។ សមត្ថភាពកត់សម្គាល់គំរូ និងកំណត់រកកត្តាជំរុញការភ្លាំងភ្លាត់ នឹងបង្កើនល្បឿន និងប្រសិទ្ធភាពនៃការឆ្លើយតប និងធានាការស្តារការភ្លាំងភ្លាត់ មុនពេលដែលបញ្ហានេះមិនអាចដោះស្រាយបានជារៀងរហូត។ កត្តាដែលបង្កជាការភ្លាំងភ្លាត់ ប្រែប្រួល និងផ្អែកតាមបរិបទ។ ដូច្នេះ ត្រូវកសាងជំនាញ និងសមត្ថភាពរបស់រដ្ឋាភិបាលមូលដ្ឋាន និងរចនាសម្ព័ន្ធគាំទ្រសហគមន៍ក្នុងការវាយតម្លៃគំរូនៃការភ្លាំងភ្លាត់ និងកត្តាបង្កប់នៅកម្រិតមូលដ្ឋាន និងផ្តល់ឧបករណ៍ដល់ពួកគេដើម្បីផ្តល់ការឆ្លើយតបតាមបរិបទ។

២. **បង្កើត/ពង្រឹងរចនាសម្ព័ន្ធសហគមន៍ ៖** សូមបង្កើតរចនាសម្ព័ន្ធគាំទ្រសហគមន៍ដូចជា WASHcoms ឬក្រុមសកម្មភាពអនាម័យ ដែលធ្វើការក្នុងសហគមន៍ផ្ទាល់ ដើម្បីកំណត់រក និងដោះស្រាយការភ្លាំងភ្លាត់ឱ្យបានឆាប់បំផុត។ ភាពនៅជិតដិតជាមួយសហគមន៍ ជួយបង្កើនការទទួលខុសត្រូវ និងធានាថា ការឆ្លើយតបមានភាពសមស្របតាមបរិបទ។ សូមពិចារណាជាមុនពីរបៀបបំផុសរចនាសម្ព័ន្ធគាំទ្រសហគមន៍ក្នុងរយៈពេលវែង ដូចជា ការបង្កប់រចនាសម្ព័ន្ធទាំងនេះក្នុងរចនាសម្ព័ន្ធរដ្ឋាភិបាលផ្លូវការ និងរបៀបតាមដានការបំពេញមុខងាររបស់រចនាសម្ព័ន្ធទាំងនេះ។

៣. **ការផ្តោតការយកចិត្តទុកដាក់លើបុគ្គលគ្រប់រូប មិនកើតឡើងដោយឯកឯងនោះទេ ៖** សូមកុំសន្មតថា យន្តការគាំទ្រសហគមន៍នឹងបំពេញតម្រូវការរបស់ប្រជាជនក្រីក្របំផុត និងងាយរងគ្រោះបំផុតបានជារៀងរហូតនោះទេ ជាពិសេសនៅពេលដែល

ស្ថានភាព ឬសម្ភារៈក្នុងមូលដ្ឋាន តម្រូវឱ្យមានការសង់បង្គន់ឡើងវិញ និងការជួសជុលច្រើនដងក្នុងមួយឆ្នាំៗ។ សូមកំណត់រកយុទ្ធសាស្ត្រជាក់លាក់ដែលកំណត់រក និងផ្តោតសំខាន់លើគ្រួសារក្រីក្របំផុត និងងាយរងគ្រោះបំផុតដើម្បីធានាថាពួកគេអាចធានានិរន្តរភាព នឹងពង្រឹងការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុងក្នុងសហគមន៍ ដែលបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុង។

៤. **ធានាថា ប្រព័ន្ធពិនិត្យតាមដានផ្តោតការយកចិត្តទុកដាក់លើការភ្លាំងភ្លាត់ ៖** សូមបង្កើតប្រព័ន្ធពិនិត្យតាមដាន ដែលមិនបញ្ចប់ត្រឹមការបញ្ជាក់ការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុង ប៉ុន្តែនៅតែបន្តផ្តល់គុណភាពទិន្នន័យចាំបាច់ដើម្បីពិនិត្យតាមដានវឌ្ឍនភាពឆ្ពោះទៅសម្រេចបានចំណុចដៅនៃលទ្ធភាពទទួលបានជាសកល ក៏ដូចជាផ្តល់បណ្តុំទិន្នន័យចាំបាច់នៅកម្រិតមូលដ្ឋានដើម្បីកំណត់រក និងដោះស្រាយការភ្លាំងភ្លាត់។

៥. **ចាត់ទុកការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុងជាចំណុចចាប់ផ្តើម ៖** សូមលើកកម្ពស់ការបន្តអនុវត្តសកម្មភាពសហគមន៍ឆ្ពោះទៅរកចំណុចដៅអនាម័យដែលគ្រប់គ្រងដោយសុវត្ថិភាព តាមរយៈការធ្វើផែនការ និងការផ្តល់ធនធានដល់យុទ្ធសាស្ត្រក្រោយការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុង។ ចំណុចដៅក្រោយការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុងពង្រឹងឥរិយាបថអនាម័យ និងជំរុញការសម្រេចបានការឆ្ពោះឡើងលើនៃកាំជណ្តើរអនាម័យគួបផ្សំនឹងសេវាអនាម័យបរិស្ថានកម្រិតខ្ពស់។ ការផ្តោតលើជំហានបន្ទាប់ជំរុញឱ្យសហគមន៍កំណត់រក និងលើកឡើងពីការភ្លាំងភ្លាត់ក្នុងដំណើរការនេះ។

**ចាំបាច់ត្រូវមានការស្រាវជ្រាវបន្ថែមទៀត ដើម្បី ៖**

- **កសាងមូលដ្ឋានចំណេះដឹងស្តីពីការដោះស្រាយការភ្លាំងភ្លាត់។** ការពិនិត្យឡើងវិញនេះកត់សម្គាល់ពីការលំបាក ក្នុងការកំណត់រកករណីជាក់លាក់ពីឯកសារមានស្រាប់ ឬពីមូលដ្ឋាន ស្តីពីរបៀបកំណត់រក និងស្តារការភ្លាំងភ្លាត់។ ឧទាហរណ៍ដែលលើកឡើងក្នុងការពិនិត្យឡើងវិញនេះ គ្រាន់តែជាចំណុចចាប់ផ្តើមប៉ុណ្ណោះ និងចាំបាច់ត្រូវមានការរៀនសូត្របន្ថែម។
- **ផ្តោតលើការភ្លាំងភ្លាត់នៃការលាងសម្អាតដៃ។** ករណីភ្លាំងភ្លាត់ភាគច្រើនដែលបានរកឃើញ ផ្តោតសំខាន់លើការបន្ទោរបង់ពាសវាលពាសកាលក្នុងបរិស្ថានចំណែកលក្ខណៈវិនិច្ឆ័យផ្សេងទៀត នៃការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុង ជាពិសេសការលាងសម្អាតដៃ ក៏ងាយនឹងភ្លាំងភ្លាត់ផងដែរ (Tyndale-Biscoe et al. 2013)[31] ។ ដូច្នេះ ចាំបាច់ត្រូវកំណត់រក និងចែករំលែក ឧទាហរណ៍នៃការអនុវត្ត ដែលស្តារការភ្លាំងភ្លាត់នៃការលាងសម្អាតដៃ។

[31] ការសម្ភាសអ្នកផ្តល់ព័ត៌មានសំខាន់ក្នុងតំបន់អាហ្វ្រិកខាងលិច និងកណ្តាល

- **ស្វែងយល់ និងដោះស្រាយការភ្លាំងភ្លាត់ក្នុងគ្រួសារ ៖** មានមូលដ្ឋានភស្តុតាងកាន់តែច្រើន ស្តីពីផលប៉ះពាល់នៃឌីណាមិកក្នុងគ្រួសារលើលទ្ធផលនៃកម្មវិធីសហគមន៍ដឹកនាំអនាម័យទាំងស្រុង។ ដូច្នេះ ចាំបាច់ត្រូវមានការស្រាវជ្រាវបន្ថែម ស្តីពីយន្តការដែលឌីណាមិកទាំងនេះបង្កជាការភ្លាំងភ្លាត់ និងមេរៀនស្តីពីរបៀបកំណត់រក និងស្តារការភ្លាំងភ្លាត់ក្នុងគ្រួសារ។
- **ដោះស្រាយការភ្លាំងភ្លាត់របស់គ្រួសារក្រីក្របំផុត ៖** គ្រួសារក្រីក្របំផុតក្នុងសហគមន៍ ច្រើនតែងាយភ្លាំងភ្លាត់ ហើយភាពក្រីក្របានគួបផ្សំជាមួយកត្តាបង្កការភ្លាំងភ្លាត់ផ្សេងទៀត។ដូច្នេះចាំបាច់ត្រូវមានមេរៀនស្តីពីវិធីសាស្ត្រនានាសម្រាប់កំណត់រក និងដោះស្រាយការភ្លាំងភ្លាត់របស់គ្រួសារក្រីក្របំផុត។
- **ធានានិរន្តរភាពរបស់ក្រុមគាំទ្រនៅមូលដ្ឋាន ដែលជាចំណុចស្នូលនៃការដោះស្រាយការភ្លាំងភ្លាត់ ៖** ការភ្លាំងភ្លាត់ដែលកើតឡើង ក្រោយការបញ្ជាក់ការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុង ច្រើនកើតឡើងបន្ទាប់ពីកម្មវិធីលែងផ្តល់ការគាំទ្រ។ តួនាទីរបស់អ្នកស្ម័គ្រចិត្តក្នុងរចនាសម្ព័ន្ធគាំទ្រសង្គមសម្រាប់ការកំណត់រក និងដោះស្រាយការភ្លាំងភ្លាត់ មានសារៈសំខាន់ណាស់ និងចាំបាច់ត្រូវមានការស្រាវជ្រាវបន្ថែមទៀតលើរបៀបធានានិរន្តភាពរបស់ពួកគេ។

## ឯកសារយោង


AMCOW (forthcoming, 2019) AfricaSan5 Conference report

Bevan J. and Thomas A. (2013) 'Developing and monitoring protocol for the elimination of open defecation in Sub-Saharan Africa', https://www.ircwash.org/resources/developing-and-monitoring-protocol-elimination-open-defecation-sub-saharan-africa (accessed 7 August 2019)

Cavill, S. with Chambers, R. and Vernon, N. (2015) 'Sustainability and CLTS: Taking Stock', *Frontiers of CLTS: Innovations and Insights* 4, Brighton: IDS

Cavill, S., Mott, J. and Tyndale-Biscoe, P., with Bond, M., Huggett, C. and Wamera, E. (2018) 'Engaging men and boys in sanitation and hygiene programmes', *Frontiers of CLTS: Innovations and Insights* 11, Brighton: IDS

Chambers, R. and Myers, J. (2016) 'Norms, Knowledge and Usage', *Frontiers of CLTS: Innovations and Insights* 7, Brighton: IDS

Cole, B. (2013) 'Participatory Design Development for Sanitation', *Frontiers of CLTS: Innovations and Insights* Issue 1, Brighton: IDS

Coombes, Y. (2016) 'User-centred latrine guidelines – integrating CLTS with sanitation marketing: a case study from Kenya to promote informed choice', in Bongartz, P., Vernon, N., and Fox, J. (eds) (2016) *Sustainable sanitation for All: Experiences, Challenges, and Innovations*, Rugby, UK: Practical Action Publishing, https://www.developmentbookshelf.com/doi/book/10.3362/9781780449272

DWSS and SNV (2017) *Options on Household Toilet Facilities for People with Disabilities and Difficulties* National Water Supply and Sanitation Training

Centre, DWSS, Nepal, http://www.snv.org/public/cms/sites/default/files/explore/download/handbook-disabilities-toilet-option-nepal.pdf
England, P. (2016) *Follow-up MANDONA: A field guide for accelerating and sustaining open defecation free communities through a Community-Led Total Sanitation approach*, Geneva: Water Supply and Sanitation Collaborative Council
Gibson, J., Eales, K. and Nsubuga-Mugga, C. (2018) *Reviewing National Sanitation to Reach Sustainable Development Goals: Uganda Sanitation Diagnostic Study Report*, Washington, DC: World Bank
Greaves, F. (2016) 'CLTS in Post-Emergency and Fragile States Settings', *Frontiers of CLTS: Innovations and Insights* 9, Brighton: IDS
House, S., Cavill, S. and Ferron, S. (2017) 'Equality and non-discrimination (EQND) in sanitation programmes at scale', Part 1 of 2, *Frontiers of CLTS: Innovations and Insights* 10, Brighton: IDS
Institute of Development Studies (2018) 'East and Southern Africa Regional Rural Sanitation Workshop' *CLTS Knowledge Hub Learning Brief* 4, Brighton: IDS
Jacob, N. (2018) *ODF+, ODF++ and Sustainability of Sanitation - Thematic Discussion Series Synthesis*, SUSANA, https://www.susana.org/en/knowledge-hub/resources-and-publications/library/details/3438
Jerneck et al. (2016) *Sanitation and Hygiene Behaviour Change at Scale: Understanding Slippage,* Geneva: Water Supply and Sanitation Collaborative Council (WSSCC)
Kohlitz, J., Carrard, N. and Willetts, J. (2019) 'Support mechanisms to strengthen equality and non-discrimination (EQND) in rural sanitation (Part 2 of 2)', *Frontiers of CLTS: Innovations and Insights* 13, Brighton: IDS
Mukherjee N. (2011) *Factors Associated with Achieving and Sustaining Open Defecation Free Communities: Learning from East Java*, World Bank, Water and Sanitation Program Research Brief
NWSSTC (2017) 'Options on Household Toilet Facilities for People with Disabilities and Difficulties. National Water Supply and Sanitation Training Centre and SNV Nepal', http://www.snv.org/public/cms/sites/default/files/explore/download/handbook-disabilities-toilet-option-nepal.pdf
Ngwale, M., DeGabriele, J. (2017) *Research Study into ODF Sustainability*, UNICEF and United Purpose Malawi
Odagiri, M., Muhammad, Z., Cronin, A., Gnilo, M., Mardikanto, A., Umam, K. and Asamou, Y. (2017) 'Enabling Factors for Sustaining Open Defecation-Free Communities in Rural Indonesia: A Cross-Sectional Study', *International Journal of Environmental Research and Public Health* 14.12, Multidisciplinary Digital Publishing Institute: 1572. https://doi.org/10.3390/ijerph14121572. https://doi.org/10.3390/ijerph14121572
Orgill-Meyer, J., Pattanayak, S., Chindarkar, N., Dickinson, K., Panda, U., Rai, S., Sahoo, B., Singha, A., Jeuland, A. (2019) *Long-term impact of a community-led sanitation campaign in India, 2005-2016* https://www.who.int/bulletin/online_first/BLT.18.221572.pdf?ua=1
Pasteur, K. (2012) 'Improving CLTS from a community perspective in Indonesia: Research summary', CLTS Foundation and Plan Indonesia, https://www.communityledtotalsanitation.org/sites/communityledtotalsanitation.org/files/CLTS_Research_Indonesia.pdf
Pasteur, K. (2017) 'Keeping Track: CLTS Monitoring, Certification and Verification', *CLTS Knowledge Hub Learning Paper*, Brighton: IDS
Regmi, A. (2016) 'Tools for embedding post-ODF sustainability: experiences from SNV Nepal', in Bongartz, P., Vernon, N., and Fox, J. (eds) (2016) *Sustainable Sanitation for All: Experiences, Challenges, and Innovations*, Rugby, UK: Practical Action Publishing, https://www.developmentbookshelf.com/doi/book/10.3362/9781780449272
Rieiro, M. (2019) 'Jirani sanitation groups: sustaining open defecation free status in

Tanzania', SNV Tanzania
Robinson, A., Bond, M., Kidd, R., Mott, J., Tyndale-Biscoe, P. (2016) 'Final Evaluation: Pan African CLTS programme 2010-2015', Plan Netherlands
Robinson, A., Gnilo, M. (2016) 'Beyond ODF: A phased approach to rural sanitation development' in Bongartz, P., Vernon, N., and Fox, J. (eds) (2016) *Sustainable Sanitation for All: Experiences, Challenges, and Innovations*, Rugby, UK: Practical Action Publishing, https://www.developmentbookshelf.com/doi/book/10.3362/9781780449272
Russpatrick, S., Tiwari, A. Markle, L., Musonda, E., Mutunda, A., Osbert, N., Pinfold, J., Winters, A., Winters, B. and Larsen, D. (2017) 'Mobility up the sanitation ladder following community-led total sanitation in rural Zambia', *Journal of Water, Sanitation, and Hygiene for Development*
Thomas A (2016) 'Strengthening post-ODF programming: reviewing lessons from Sub-Saharan Africa' in Bongartz, P., Vernon, N., and Fox, J. (eds) (2016) *Sustainable Sanitation for All: Experiences, Challenges, and Innovations*, Rugby, UK: Practical Action Publishing, https://www.developmentbookshelf.com/doi/book/10.3362/9781780449272
Tyndale-Biscoe P., Bond M., and Kidd R. (2013). "Plan ODF Sustainability Study". Plan International, https://www.communityledtotalsanitation.org/sites/communityledtotalsanitation.org/files/Plan_International_ODF_Sustainability_Study.pdf
UN-Habitat (2017) *Study on Sustainability of Open Defecation Free Communities in GSF Supported Program Districts, Nepal 2016*
UNICEF (2014) 'Sustainability of ODF Practices in Kenya', *UNICEF WASH Field Note* series, https://www.unicef.org/esaro/UNICEF-FN-ODF-Sustainability.pdf
UNICEF (2016) *Equity, Scalability and Sustainability in UNICEF WASH Programming: Evidence from UNICEF Evaluations 2007-2015*, UNICEF Evaluation Office, July 2016
UNICEF (2017) *UNICEF Field Notes on Community Approaches to Total Sanitation: Learning from 5 Country Programmes*, New York: UNICEF
UNICEF Philippines (2016) *Coping strategies on damaged toilet facilities: The case of Aroroy, Masbate*, draft report copy from UNICEF Philippines team
USAID (2017) 'Madagascar Rural Access to New Opportunities for Health and Prosperity (RANO-HP) Sustainability Evaluation', WASH Sustainability Evaluation Series – Water Communications and Knowledge Management (CKM) Project
USAID (2018) *An Examination of CLTS's Contributions toward Sanitation*. Washington, DC.: USAID Water, Sanitation, and Hygiene Partnerships and Sustainability (WASHPaLS) Project
Wamera, E. (2016) 'Who is managing the post-ODF process in the community? A case-study of Nambale sub-county in western Kenya', in Bongartz, P., Vernon, N., and Fox, J. (eds) *Sustainable Sanitation for All: Experiences, Challenges, and Innovations*, Rugby, UK: Practical Action Publishing, https://www.developmentbookshelf.com/doi/book/10.3362/9781780449272
WaterAid and DDSP (2016) 'How to conduct a WASH Accessibility and Safety Audit', WaterAid and DDSP Cambodia https://washmatters.wateraid.org/publications/how-to-conduct-a-wash-accessibility-and-safety-audit
Wilbur, J. and Jones, H. (2014) 'Disability: Making CLTS Fully Inclusive', *Frontiers of CLTS: Innovations and Insights* 3, Brighton: IDS
WSP-UNICEF (2015) *Management of Child Feces: Current Disposal Practices*, https://www.wsp.org/sites/wsp/files/publications/WSP-CFD-Summary-Brief.pdf
WSSCC (2019) 'Measuring the last mile: discussing new sustainability and equality data across at-scale behaviour change programmes', PowerPoint presentation made at IRC *All Systems Go!* Symposium

## អំពីកម្រងឯកសារនេះ

នេះជាកម្រងកំណត់សម្គាល់ខ្លីៗដែលផ្តល់ការណែនាំជាក់ស្តែងស្តីពីមធ្យោបាយ
និងវិធីសាស្ត្រថ្មីៗ និងការពិចារណាពីបញ្ហាផ្សេងទៀត។
យើងខ្ញុំរីករាយនឹងទទួលយកមតិ គំនិត និងការលើកឡើងទាំងឡាយ។
សូមទាក់ទងមកយើងខ្ញុំតាមអាសយដ្ឋាន ៖ SLH@ids.ac.uk។

## កម្រងឯកសារផ្សេងទៀតដែលបានបោះពុម្ពផ្សាយ

**កម្រងឯកសារទាំងអស់អាចរកបានតាមគេហទំព័រ ៖**
www.https://sanitationlearninghub.org/series/frontiers-of-sanitation/

**ឯកសារទី ១ ៖** Cole, B. (2013) 'Participatory design development for sanitation'
**ឯកសារទី ២ ៖** Maulit, J.A. (2014) 'How to trigger for handwashing with soap'
**ឯកសារទី ៣ ៖** Wilbur, J and Jones, H. (2014) 'Disability: Making SLH fully inclusive'
**ឯកសារទី ៤ ៖** Cavill, S. with Chambers, R. and Vernon, N. (2015) 'Sustainability and SLH: Taking stock'
**ឯកសារទី ៥ ៖** House, S. and Cavill, S. (2015) 'Making sanitation and hygiene safer: Reducing vulnerabilities to violence'
**ឯកសារទី ៦ ៖** Roose, S., Rankin, T. and Cavill, S. (2015) 'Breaking the next taboo: Menstrual hygiene within SLH'
**ឯកសារទី ៧ ៖** Chambers, R. and Myers, J. (2016) 'Norms, knowledge and usage'
**ឯកសារទី ៨ ៖** Musembi, C. and Musyoki, S. (2016) 'SLH and the right to sanitation'
**ឯកសារទី ៩ ៖** Greaves, F. (2016) 'SLH in post-emergency and fragile states settings'
**ឯកសារទី ១០ ៖** House, S., Cavill, S. and Ferron, S. (2017) 'Equality and non-discrimination (EQND) in sanitation programmes at scale'
**ឯកសារទី ១១ ៖** Cavill, S., Mott, J. and Tyndale-Biscoe, P., with Bond, M., Huggett, C. and Wamera, E. (2018) 'Engaging men and boys in sanitation and hygiene programmes', Frontiers of SLH: Innovations and Insights 11, Brighton: IDS
**ឯកសារទី ១២ ៖** Myers, J. (ed) (2019 'Rural Sanitation in Africa: Challenges, Good Practices and Ways Forward'
**ឯកសារទី ១៣ ៖** Kohlitz, J., Carrard, N. and Willetts, J. (2019) 'Support mechanisms to strengthen equality and non-discrimination (EQND) in rural sanitation (Part 2 of 2)

# ការដោះស្រាយការភ្លាំងភ្លាត់

ការភ្លាំងភ្លាត់នៃស្ថានភាពបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុង ត្រូវបានកត់សម្គាល់ជាបញ្ហាប្រឈមចំពោះនិរន្តរភាពក្នុងកម្មវិធី និងអន្តរាគមន៍ជាច្រើន។ មានឯកសារជាច្រើនលើកឡើងពីរបៀបបង្កើតកម្មវិធីសហគមន៍ដឹកនាំអនាម័យទាំងស្រុងប្រកបដោយនិរន្តរភាពដើម្បីទប់ស្កាត់ការភ្លាំងភ្លាត់។ ឯកសារទី ១៤ ក្នុងកម្រងឯកសារ "ព្រំដែននៃកម្មវិធីសហគមន៍ដឹកនាំអនាម័យទាំងស្រុង" ផ្តោតលើវិធានការនានាសម្រាប់ការភ្លាំងភ្លាត់ដែលកើតឡើង។

ឯកសារនេះចែកចេញជាពីរផ្នែក។ ផ្នែកទីមួយផ្តោតលើរបៀបកំណត់ការភ្លាំងភ្លាត់ បង្ហាញពីក្របខណ្ឌសម្រាប់ការកំណត់រកគំរូនៃការភ្លាំងភ្លាត់ និងពិនិត្យឡើងវិញលើកត្តាដែលរួមចំណែកបង្កការភ្លាំងភ្លាត់។ ផ្នែកទីពីរលើកឡើងពីឧទាហរណ៍ករណី ៦ ស្តីពីបទពិសោធន៍នៃការភ្លាំងភ្លាត់នៅមូលដ្ឋាន និងចំណាត់ការនានាក្នុងការស្តារការភ្លាំងភ្លាត់។ យើងរំពឹងថា ការពិនិត្យឡើងវិញនេះនឹងផ្តល់មូលដ្ឋានសម្រាប់ការរៀនសូត្រ និងការចែករំលែកជាប្រព័ន្ធស្តីពីការភ្លាំងភ្លាត់ដើម្បីជាគ្រឹះសម្រាប់ការរៀបចំកម្មវិធី និងការអនុវត្តនៅពេលបច្ចុប្បន្ន និងថ្ងៃអនាគត។

## អំពីអ្នកនិពន្ធ

Sophie Hickling ជាអ្នកឯកទេសផ្នែកអនាម័យដែលចាប់អារម្មណ៍លើការកសាងសមត្ថភាពកម្រិតបុគ្គល ក្រុម និងស្ថាប័ន។ អ្នកស្រីបានធ្វើការជាមួយអង្គការជាច្រើនទាំងក្នុងបរិបទអភិវឌ្ឍន៍ និងបរិបទមនុស្សធម៌។ បច្ចុប្បន្នអ្នកស្រីជាសមាជិកជាន់ខ្ពស់ (senior associate) នៃទីប្រឹក្សា MGអាហ្រ្វិក។



Illustration by Jamie Eke

the sanitation learning hub

វិទ្យាស្ថានសិក្សាអភិវឌ្ឍន៍ (IDS) នៃសាកលវិទ្យាល័យ Sussex, Brighton BN1 9RE
គេហទំព័រ ៖ https://sanitationlearninghub.org/
អ៊ីមែល ៖ SLH@ids.ac.uk
Twitter ៖ @SanitationLearningHub
ទូរស័ព្ទ ៖ +44 (0) 1273 606261
ទូរសារ ៖ +44 (0) 1273 621202

IDS ជាក្រុមហ៊ុនសប្បុរសធម៌ក្រោមការធានាមានកម្រិត ៖ Registered Charity No. 306371; Registered in England 877338; VAT No. GB 350 899914

## ស្វែងយល់បន្ថែមទៀត

ជាវ ព្រឹត្តិប័ត្រកម្មវិធីសហគមន៍ដឹកនាំអនាម័យទាំងស្រុង (SLH ចែករំលែកបទពិសោធន៍របស់អ្នក និងរួមចំណែកដល់គេហទំព័ររបស់ SLH តាម់អ៊ីមែល ៖ SLH@ids.ac.uk